ក្រសួងអភិវឌ្ឍន៍ជនបទ

# ផែនការសកម្មភាពជាតិ
# ស្ដីពី
# ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ
# ឆ្នាំ ២០១៩-២០២៣

ខែមករា ឆ្នាំ ២០១៩

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីសម្រេចបានទស្សនវិស័យនៃការ ផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ៖ “នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព” ដូចដែលបានកំណត់នៅក្នុងគោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យឆ្នាំ ២០០៣។

វិស័យនេះបានបង្កើតផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទឆ្នាំ ២០១៤-២០២៥ ជាឯកសារណែនាំចម្បង និងផែនការសកម្មភាពជាតិ ស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទឆ្នាំ ២០១៤-២០១៨ បានធ្វើឱ្យសម្រេចបាននូវទស្សនវិស័យឆ្នាំ ២០២៥។

ផែនការសកម្មភាពជាតិលើកទី១ (ឆ្នាំ ២០១៤-២០១៨) សម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន។ អត្រាគ្របដណ្តប់អនាម័យជនបទ បានកើនឡើងចំនួន ៣០,៣ %ពីទិន្នន័យគោលដែលមាន ៤០,៩ %[១]។ គិតត្រឹមឆ្នាំ ២០១៧ អត្រានេះគឺ ៧១,២ %[២] ដែលធ្វើឱ្យប្រជាពលរដ្ឋប្រមាណ ៤ លាននាក់បន្ថែមទៀត ឬ ៩០៩.០៩០ គ្រួសារ/ខ្នងផ្ទះ ទទួលបានអនាម័យដែលមានការកែលម្អ។ ការផ្គត់ផ្គង់ទឹកស្អាតបានកើនឡើងក្នុងអត្រាទាបជាងនេះគឺ ១២,១ % ពោលគឺកើនឡើងពី ៤៦,៦ %[៣] ដល់ ៥៨,៧ % ក្នុងឆ្នាំ ២០១៧ ដោយបានធ្វើឱ្យប្រជាពលរដ្ឋប្រមាណ ១,៥៩ លាននាក់ ឬ ៣៦១.៣៦៤ គ្រួសារ/ខ្នងផ្ទះ ទទួលបានទឹកស្អាតដែលមានការកែលម្អ។ ទោះបីជាយ៉ាងនេះក្តី នៅតែមានកត្តាប្រឈមជាច្រើន ដូចជាការបែងចែកសេវាគឺមិនទាន់មានភាពស្មើគ្នា ដោយហេតុថាប្រជាពលរដ្ឋនៅក្នុងឃុំ និងខេត្តដាច់ស្រយាល គ្រួសារ/ខ្នងផ្ទះក្រីក្រនិងប្រជាពលរដ្ឋដែលរស់នៅក្នុងបរិស្ថានប្រឈមទទួលបានសេវាទាបជាងគេខ្លាំង។

ផែនការសកម្មភាពជាតិលើកទីពីរ ស្តីពីការការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ សម្រាប់ឆ្នាំ ២០១៩-២០២៣ មានគោលបំណងជួយឱ្យប្រជាពលរដ្ឋនៅជនបទក្នុងប្រទេសកម្ពុជាទទួលបានទឹកស្អាត និងបង្គន់អនាម័យប្រកបដោយសមធម៌ និរន្តរភាព និងសុវត្ថិភាព។ ការផ្តោតទៅលើសមធម៌ នឹងត្រូវបានពង្រឹងតាមរយៈសកម្មភាពជាក់លាក់មួយចំនួន ដែលផ្តោតគោលដៅលើគ្រួសារ/ខ្នងផ្ទះក្រីក្រ និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលមានការលំបាក។

ក្នុងគោលដៅធានាថា ៩០ % នៃប្រជាពលរដ្ឋនៅតំបន់ជនបទ ទទួលបានសេវាទឹកស្អាត និងអនាម័យប្រកបដោយសមធម៌ សុវត្ថិភាព និងតម្លៃសមរម្យ ផែនការសកម្មភាពជាតិលើកទីពីរ នឹងជំរុញវិស័យនេះឱ្យខិតកាន់តែជិតទៅនឹងទស្សនវិស័យនៃការទទួលបានសេវានេះជាសកល។ ផែនការនេះនឹងរួមចំណែកដល់ការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ជាពិសេសគោលដៅទី៦“ធានាការផ្គត់ផ្គង់ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវទឹកស្អាត និងអនាម័យសម្រាប់ប្រជាពលរដ្ឋគ្រប់រូប” ក៏ដូចជាគោលដៅដែលទាក់ទងនឹងការអប់រំ សុខភាព សមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

---

[១] ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៣។
[២] ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៧។
[៣] ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៣។

ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ឆ្នាំ ២០១៩-២០២៣ ត្រូវបានបង្កើតឡើងក្រោមការសម្របសម្រួលជារួមដោយក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធជាច្រើនពីគ្រប់លំដាប់ថ្នាក់។ ដូចនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ និងសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្តការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ និងអង្គការមិនមែនរដ្ឋាភិបាល ឱ្យបន្តការគាំទ្រអនុវត្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃផែនការសកម្មភាពថ្នាក់ជាតិ និងថ្នាក់ខេត្ត។

ថ្ងៃសុក្រ ១៣រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

# ពាក្យកាត់ និងអក្សរកាត់

| | | |
|---|---|---|
| **BCC** | Behaviour Change Communication | ការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង |
| **CDP** | Capacity Development Plan | ផែនការអភិវឌ្ឍន៍សមត្ថភាព |
| **CLTS** | Community-Led Total Sanitation | សហគមន៍ដឹកនាំអនុវត្តអនាម័យ |
| **CSES** | Cambodia Socio Economic Survey | ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា |
| **D&D** | Decentralization and Deconcentration | វិមជ្ឈការនិងវិសហមជ្ឈការ |
| **DORD** | District Office of Rural Development | ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| **DRHC** | Department of Rural Health Care | នាយកដ្ឋានថែទាំសុខភាពជនបទ |
| **DRWS** | Department of Rural Water Supply | នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ |
| **EMIS** | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ |
| **ID Poor** | Identification of Poor Households | អត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| **MIS** | Management Information System | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| **MoH** | Ministry of Health | ក្រសួងសុខាភិបាល |
| **MoEYS** | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| **MRD** | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **NAP** | National Action Plan | ផែនការសកម្មភាពជាតិ |
| **NGO** | Non-Government Organization | អង្គការមិនមែនរដ្ឋាភិបាល |
| **NSP** | National Strategic Plan (for RWSSH) 2014-2025 | ផែនការយុទ្ធសាស្ត្រជាតិ (សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ) ឆ្នាំ២០១៤-២០២៥ |
| **ODF** | Open Defecation Free | បញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល |
| **PAP** | Provincial Action Plan | ផែនការសកម្មភាពខេត្ត |
| **PDRD** | Provincial Department of Rural Development | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |

# ពាក្យកាត់ និងអក្សរកាត់

| | | |
|---|---|---|
| **PWG** | Provincial Working Group | ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត |
| **PWG-S** | Secretariat of PWG | លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **RuSH** | Rural Sanitation and Hygiene | អនាម័យជនបទ |
| **RWSSH** | Rural Water Supply, Sanitation and Hygiene | ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ |
| **SDG** | Sustainable Development Goal | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **TWG** | Technical Working Group | ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ |
| **TWG-S** | Secretariat of the TWG | លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសថ្នាក់ជាតិ |
| **UNICEF** | United Nations Children's Fund | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) |
| **WASH** | Water, Sanitation and Hygiene | ទឹកស្អាត និងអនាម័យ |
| **WSP** | Water Safety Plan | ផែនការសុវត្ថិភាពទឹក |
| **WHO** | World Health Organization | អង្គការសុខភាពពិភពលោក |

# និយមន័យ

| សេវាទឹកផឹក | |
|---|---|
| ទឹកផឹកដែលមានសុវត្ថិភាព | គ្មានមេរោគបង្កជំងឺ និងគ្មានសារជាតិគីមីពុលលើសកម្រិត |
| សេវាទឹកផឹកដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | ទឹកផឹកមកពីប្រភពទឹកដែលមានការកែលម្អ ដែលស្ថិតនៅក្នុងបរិវេណផ្ទះអគារ មានគ្រប់ពេលត្រូវការ គ្មានមេរោគបង្កជំងឺ និងគ្មានសារជាតិគីមីពុលលើសកម្រិត។ |
| សេវាទឹកផឹកជាមូលដ្ឋាន | ទឹកផឹកមកពីប្រភពទឹកដែលមានការកែលម្អ រយៈពេលនៃការទៅយក/ដងទឹកមិនលើសពី ៣០នាទី/ដង រួមទាំងពេលវេលារង់ចាំផងដែរ។ |
| សេវាទឹកមានកម្រិត | ទឹកផឹកមកពីប្រភពទឹកដែលមានការកែលម្អ រយៈពេលនៃការទៅយក/ដងទឹកលើសពី ៣០នាទី/ដង រួមទាំងពេលវេលារង់ចាំផងដែរ។ |
| ប្រភពទឹកដែលមានការកែលម្អ | ប្រភពទឹកដែលមានការកែលម្អ រួមមាន៖ ប្រព័ន្ធចែកចាយទឹកតាមទុយោ និងអណ្តូងស្នប់ដែលបានសាងសង់តាមបទដ្ឋានបច្ចេកទេស អណ្តូងលូដែលមានការការពារ ទឹកផុសដែលមានការការពារ ទឹកភ្លៀងមានប្រព័ន្ធទរ និងស្តុកត្រឹមត្រូវ និងទឹកបឺដុងដែលបានពីស្ថានីយ៍បន្សុទ្ធ ។ |
| ប្រភពទឹកដែលគ្មានការកែលម្អ | ប្រភពទឹកដែលគ្មានការកែលម្អ រួមមាន៖ អណ្តូងលូ ទឹកផុសគ្មានការការពារ ប្រព័ន្ធចែកចាយទឹកតាមទុយោ និងអណ្តូងស្នប់ដែលបានសាងសង់ខុសបទដ្ឋានបច្ចេកទេស និងទឹកលើដី (ដូចជា បឹង ទន្លេ ស្ទឹង ស្រះ ព្រែក ទំនប់ធារាសាស្ត្រ) ដែលគ្មានការការពារ។ |
| សេវាទឹកផឹកជាមូលដ្ឋានសម្រាប់សាលារៀន | ទឹកសម្រាប់ផឹកដែលបានមកពីប្រភពកែលម្អ មាននៅតាមសាលារៀន។ |
| ប្រភពទឹកជាមូលដ្ឋានសម្រាប់មណ្ឌលសុខភាព | ទឹកសម្រាប់ផឹកដែលបានមកពីប្រភពកែលម្អ មាននៅតាមមណ្ឌលសុខភាព។ |
| ការប្រើប្រាស់ និងការថែទាំ | ការប្រើប្រាស់ និងការថែទាំ សំដៅទៅលើការរៀបចំ ការគ្រប់គ្រង ការចាត់ចែងប្រពន្ធ័ផ្គង់ផ្គត់ទឹកជនបទឱ្យមាននិរន្តរភាព ។ |
| ផែនការសុវត្ថិភាពទឹក (WSP) | គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពមួយក្នុងការធានាសុវត្ថិភាពនៃការផ្គង់ផ្គត់ទឹកផឹក។ វាគឺជាការវាយតម្លៃគ្រប់ជ្រុងជ្រោយលើហានិភ័យ និងគ្រប់គ្រងហានិភ័យគ្រប់ជំហានចាប់ពីប្រភពទឹករហូតដល់ការប្រើប្រាស់ចុងក្រោយ។ |

| សេវាអនាម័យ | |
|---|---|
| សេវាអនាម័យ | សំដៅទៅលើការគ្រប់គ្រងលាមកដែលចេញពីគ្រឹះស្ថាន/អគារ ដែលប្រើប្រាស់ដោយបុគ្គល តាមរយៈការប្រមូលយក និងការដឹកជញ្ជូនលាមកដើម្បីធ្វើប្រព្រឹត្តិកម្ម និងការបញ្ចេញចោលចុងក្រោយ ឬការប្រើប្រាស់ឡើងវិញ។ |
| ប្រព័ន្ធអនាម័យដែលបានកែលម្អ | ប្រព័ន្ធដែលត្រូវបានរៀបចំឡើងដើម្បីធ្វើការញែកលាមកប្រកបដោយអនាម័យមិនឱ្យប៉ះពាល់ជាមួយមនុស្ស។ ប្រព័ន្ធដែលបានកែលម្អរួមមាន៖ បង្គន់កាច់ទឹក/ចាក់ទឹកប្រព័ន្ធលូកាច់ទឹករហូតដល់ទុយោ អាងស្តុកលាមកឬបង្គន់រណ្តៅ បង្គន់រណ្តៅដែលបានកែលម្អដោយមានខ្យល់ចេញ-ចូល បង្គន់ទុកលាមកឱ្យរលួយឬបង្គន់រណ្តៅដែលមានគម្របបេតុងគ្របពីលើ។ |
| សេវាអនាម័យជាមូលដ្ឋាន | ការប្រើប្រព័ន្ធដែលមានការកែលម្អ ដែលមិនប្រើរួមគ្នាជាមួយគ្រួសារ/ខ្នងផ្ទះផ្សេងទៀត |
| សេវាអនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | ប្រព័ន្ធដែលបានកែលម្អឯកជន ដែលក្នុងនោះកាកសំណល់លាមកត្រូវបានបោះចោលដោយសុវត្ថិភាពនៅនឹងទីតាំងផ្ទាល់ឬដឹកជញ្ជូន និងប្រព្រឹត្តិកម្មនៅខាងក្រៅទីតាំងបន្ថែមជាមួយកន្លែងលាងសម្អាតដៃដែលមានទឹកនិងសាប៊ូ។ |
| ប្រព័ន្ធ/បង្គន់អនាម័យដែលគ្មានការកែលម្អ | រួមមាន បង្គន់រណ្តៅដែលគ្មានគម្របគ្របពីលើ បង្គន់ព្យួរ (បង្គន់ជុះទៅក្នុងទឹកដោយផ្ទាល់) និងបង្គន់ធុង |
| សេវាអនាម័យដែលមានកម្រិត | ប្រព័ន្ធដែលមានការកែលម្អ ប្រើរួមគ្នាជាមួយគ្រួសារ/ខ្នងផ្ទះផ្សេងទៀត |
| សេវាអនាម័យជាមូលដ្ឋានសម្រាប់សាលារៀន | ប្រព័ន្ធអនាម័យដែលមានការកែលម្អនៅតាមសាលារៀន ដែលបែងចែកតាមភេទដាច់ដោយឡែកពីគ្នា និងអាចប្រើបាន (មានសម្រាប់ប្រើ មានដំណើរការ និងមានលក្ខណៈឯកជន) |
| សេវាអនាម័យជា មូលដ្ឋានសម្រាប់គ្រឹះស្ថានថែទាំសុខភាព | ប្រព័ន្ធអនាម័យដែលបានកែលម្អនិងអាចប្រើប្រាស់បាន ដែលមានបង្គន់យ៉ាងតិចមួយសម្រាប់តែបុគ្គលិក មានបង្គន់ដែលបែងចែកតាមភេទដាច់ដោយឡែកពីគ្នាយ៉ាងតិចមួយ ដែលមានសម្ភារអនាម័យពេលមានរដូវ និងមានបង្គន់យ៉ាងតិចមួយសម្រាប់អ្នកប្រើដែលមានកម្រិតភាពចល័ត (ពិបាកក្នុងការធ្វើចលនាបំលាស់ទី) |
| OBA<br>(ជំនួយផ្អែកលើលទ្ធផល) | ប្រភេទមួយនៃហិរញ្ញប្បទានផ្អែកលើលទ្ធផល ដែលក្នុងនោះ ជំនួយត្រូវបានផ្តល់ដល់អ្នកអនុវត្តរដ្ឋបាលថ្នាក់មូលដ្ឋាន/អ្នកផ្តល់សេវាអនាម័យ ឬដល់គ្រួសារមួយ បន្ទាប់ពីបានសម្រេចធាតុចេញ ឬលទ្ធផលដែលបានកំណត់ជាមុន។ ប្រាក់បង្វិលជូនអតិថិជន (ចំនួនទឹកប្រាក់ថេរដែលត្រូវបានសងសម្រាប់ការចំណាយដែលបានធ្វើឡើងដោយតួអង្គមួយ) គឺជាឧទាហរណ៍ទូទៅមួយនៃ OBA នៅកម្រិតគ្រួសារ/ខ្នងផ្ទះ។ |

| | |
|---|---|
| ទីផ្សារអនាម័យ | ការអភិវឌ្ឍទីផ្សារអនាម័យវិស័យឯកជន ដែលក្នុងនោះ អ្នកប្រើប្រាស់ចូលរួមបដិភាគជាប្រាក់ទាំងស្រុងឬមួយផ្នែក (ដោយមានការសន្សំ និង/ឬ សមមូលសាច់ប្រាក់) សម្រាប់ទុកទិញ សាងសង់ ជួសជុលកែលម្អ និង/ឬ ការថែទាំបង្គន់។ និយមន័យនេះគឺផ្អែកទៅលើនិយមន័យនៃ "ការផ្សព្វផ្សាយទីផ្សារអនាម័យ" ពោលគឺការពង្រឹងការផ្គត់ផ្គង់ដោយការកសាងសមត្ថភាពរបស់វិស័យឯកជន ដោយមានការចូលរួមបដិភាគជាប្រាក់ពីអ្នកប្រើ។ |
| **សេវាអនាម័យខ្លួនប្រាណ** | |
| អនាម័យខ្លួនប្រាណ | សំដៅលើលក្ខខណ្ឌនិងការអនុវត្តនានា ដែលជួយថែរក្សាសុខភាពនិងបង្ការការរីករាលដាលជំងឺឆ្លង រួមទាំងការលាងសម្អាតដៃ ការគ្រប់គ្រង អនាម័យពេលមានរដូវ និងអនាម័យចំណីអាហារ។ |
| អនាម័យជាមូលដ្ឋាន | ការមានកន្លែងលាងសម្អាតដៃនៅក្នុងបរិវេណដែលមានទឹក និងសាប៊ូ។<br>**កំណត់សម្គាល់៖** កន្លែងលាងសម្អាតដៃអាចនៅជាប់មួយកន្លែង ឬចល័ត ហើយមានចានសម្រាប់លាងសម្អាតដៃ មានទឹកម៉ាស៊ីន មានធុងដែលមានរ៉ូប៊ីណេ មានប៊ីដុងចោះរន្ធព្យួរ (tippy-taps) និងពាង ឬអាង ដែលត្រូវបានបង្កើតឡើងសម្រាប់ប្រើលាងសម្អាតដៃ។<br>សាប៊ូរួមមានសាប៊ូដុំ សាប៊ូទឹក និងសាប៊ូម្សៅ ប៉ុន្តែមិនរួមបញ្ចូលផេះ ដីខ្សាច់ ឬសារធាតុលាងដៃផ្សេងទៀតទេ។ |
| ពុំមានសេវាអនាម័យខ្លួនប្រាណ | គ្មានកន្លែងលាងសម្អាតដៃនៅក្នុងបរិវេណ |
| សេវាអនាម័យមានកម្រិត | ការមានកន្លែងលាងសម្អាតដៃនៅក្នុងបរិវេណ មានទឹកតែគ្មានសាប៊ូ |
| សេវាអនាម័យខ្លួនប្រាណជាមូលដ្ឋានសម្រាប់សាលារៀន | កន្លែងលាងសម្អាតដៃដែលមានដំណើរការ មានទឹក និងសាប៊ូនៅក្នុងសាលារៀន |
| សេវាលាងសម្អាតដៃជាមូលដ្ឋានសម្រាប់គ្រឹះស្ថានថែទាំសុខភាព | មានកន្លែងលាងសម្អាតដៃដែលមានដំណើរការ នៅកន្លែងថែទាំមួយឬច្រើន ហើយស្ថិតនៅចម្ងាយប្រាំម៉ែត្រពីបង្គន់។<br>កន្លែងលាងសម្អាតដៃ គឺជាឧបករណ៍ដែលសម្រួលឱ្យបុគ្គលិក និងអ្នកជំងឺធ្វើការលាងសម្អាតដៃរបស់ពួកគេប្រកបដោយប្រសិទ្ធភាព ដោយប្រើទឹកពីរ៉ូប៊ីណេ និងសាប៊ូដូចជា ចានលាងដៃដែលមានរ៉ូប៊ីណេ ស៊ីទែនទឹក ធុងទឹកដែលមានរ៉ូប៊ីណេ ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត។ ដបដាក់ទឹកអាល់កុលសម្រាប់លាង ក៏ជាឧបករណ៍លាងសម្អាតដៃដែរ មិនថាដាក់ជាប់មួយកន្លែង ឬចល័តឡើយ។ |

| ពាក្យបច្ចេកទេសអន្តរវិស័យ | |
|---|---|
| តម្លៃសមរម្យ | ការបង់ប្រាក់សម្រាប់សេវា ដែលមិនផ្តល់ជាឧបសគ្គក្នុងការទទួលបាន ឬរារាំងមនុស្ស មិនឱ្យបំពេញតម្រូវការជាមូលដ្ឋានរបស់ពួកគេ |
| សមធម៌ | សំដៅលើការកាត់បន្ថយជាបន្តបន្ទាប់ និងការលុបបំបាត់វិសមភាពរវាងប្រជាពលរដ្ឋ ផ្សេងៗ |
| បរិស្ថានប្រឈម | លក្ខខណ្ឌភូមិសាស្ត្រនិងបរិស្ថានលំបាកៗ ដូចជា តំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ ដង្កើមទឹកក្រោមដីរាក់ តំបន់ខ្វះខាតទឹក ភូមិ បណ្តែតទឹក តំបន់រស់នៅតាមដងស្ទឹង/ទន្លេ/ ដៃសមុទ្រ តំបន់សំណង់មិនរៀបរយ និងតំបន់មានថ្ម |
| ថវិកាតាមកម្មវិធី | ប្រព័ន្ធថវិកាផ្អែកលើធាតុចេញ/ទិន្នផល (ធាតុចេញនិងលទ្ធផល)-ការផ្លាស់ប្តូរប្រព័ន្ធ ថវិកាចេញពីប្រព័ន្ធធាតុចូលនិងប្រព័ន្ធប្រមូលផ្តុំថ្នាក់កណ្តាលពីមុនមក។ |

# មាតិកា


**ពាក្យកាត់និងអក្សរកាត់....................................................................................................III**

**និយមន័យ..................................................................................................................V**

**១.**
**សេចក្តីផ្តើម...................................................................................................................1**
១.១ សារតារបស់វិស័យ.......................................................................................................1
១.២ អាទិភាពនៃការអភិវឌ្ឍដែលត្រូវដោះស្រាយ.......................................................................2
១.៣ ដំណើរការនៃការបង្កើត NAP II ......................................................................................4
១.៤ រចនាសម្ព័ន្ធ NAP II ...................................................................................................4

**២.**
**ការវិភាគស្ថានភាព .......................................................................................................6**
២.១ ស្ថានភាពបច្ចុប្បន្នរបស់វិស័យ ........................................................................................6
២.២ កត្តាប្រឈម ..............................................................................................................7

**៣.**
**ទិសដៅជាយុទ្ធសាស្ត្ររបស់វិស័យ...................................................................................13**
៣.១ ទិសដៅជាយុទ្ធសាស្ត្រ...................... ....................................................................13
៣.២ គោលការណ៍ណែនាំជាតិសម្រាប់អនុវត្ត NAP II ...............................................................16
៣.៣ លទ្ធផលរំពឹងទុក.........................................................................................................17
៣.៤ ការដោះស្រាយបញ្ហាអន្តរវិស័យ .......................................................................................23
៣.៥ RWSSH-PAPs ឆ្នាំ ២០១៩-២០២៣................................................................................24
៣.៦ គម្រោងពេលសម្រាប់អនុវត្តន៍...........................................................................................26
៣.៧ ការសន្មតសំខាន់ៗ........................................................................................................27

**៤.**
**ការរៀបចំស្ថាប័នសម្រាប់ការអនុវត្ត.................................................................................28**
4.1 ការរៀបចំស្ថាប័ន ...........................................................................................................28
4.2 ការរៀបចំសម្រាប់និរន្តរភាព ..............................................................................................31

**៥.**
**ហិរញ្ញប្បទាន ...............................................................................................................32**

**៦.**
**ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ..........................................................................37**

៧. សន្និដ្ឋាន ..... 39
ឧបសម្ព័ន្ធទី I: ម៉ាទ្រីសត្រួតពិនិត្យ តាមដានលទ្ធផលនៃការអនុវត្ត ..... 42
ឧបសម្ព័ន្ធ IA: បំពេញបន្ថែមទៅលើម៉ាទ្រីសត្រួតពិនិត្យ តាមដានលទ្ធផលនៃការអនុវត្ត ..... 53
ឧបសម្ព័ន្ធទី II: ការប៉ាន់ស្មានតម្រូវការចំណាយប្រចាំឆ្នាំ ..... 64

# តារាង

តារាងទី ១: ទឹកស្អាត និងអនាម័យនៅក្នុងសាលារៀន ..... 8
តារាងទី ២: គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ..... 14
តារាងទី ៣: NAP II - លទ្ធផលរំពឹងទុក សូចនាករ និងចំណុចដៅ ..... 17
តារាងទី ៤: កម្រងសកម្មភាព ..... 18
តារាងទី ៥: លទ្ធផលរំពឹងទុកធាតុចេញ ..... 20
តារាងទី ៦: ក្របខណ្ឌអនុវត្តរបស់ស្ថាប័ន ..... 29
តារាងទី ៧: តម្រូវការចំណាយប៉ាន់ស្មាន ផ្អែកតាមធាតុចេញ ..... 32
តារាងទី ៨: សមាសធាតុ វិធីសាស្ត្រប៉ាន់ស្មានចំណាយ NAP II ដោយប្រៀបធៀបជាមួយ NAP I និង SDA ..... 34
តារាងទី ៩: ចំណាយប៉ាន់ស្មានប្រភពថវិកាសាធារណៈប្រចាំឆ្នាំ និងគម្លាតថវិកាសម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ..... 35
តារាងទី ១០: កាលវិភាគសម្រាប់ការពិនិត្យឡើងវិញលើលទ្ធផលនៃការអនុវត្ត ..... 37

# រូបភាព

បភាពទី ១: រចនាសម្ព័ន្ធនៃ NAP II - RWSSH ..... 5
រូបភាពទី ២: ស្ថានភាពសូចនាករលទ្ធផលរំពឹងទុក ឆ្នាំ២០១៩-២០១៨ ..... 6
រូបភាពទី ៣: វិសមភាពសេវាការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ..... 7
រូបភាពទី ៤: ចំណុចដៅនៃ PAP - សេវាផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន ..... 25
រូបភាពទី ៥: ចំណុចដៅនៃ PAP - សេវាអនាម័យ/សុខភាពជាមូលដ្ឋាន ..... 25
រូបភាពទី ៦: ចំណុចដៅនៃ PAP - សេវាអនាម័យខ្លួនប្រាណជាមូលដ្ឋាន ..... 26

# សេចក្តីសង្ខេបរួម

ផែនការសកម្មភាពជាតិទីពីរ សម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទត្រូវបានរៀបចំឡើង ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់ជាក្របខណ្ឌមួយសម្រាប់ពន្លឿនការកែលម្អការផ្គត់ផ្គង់ទឹក ការសំអាត និង អនាម័យជនបទ ។ ផែនការនេះគឺជាមគ្គុទ្ទេសក៍មួយសម្រាប់រាជរដ្ឋាភិបាលនិងអង្គការដៃគូ ធ្វើការរៀបចំផែនការ អភិវឌ្ឍន៍ និងគ្រប់គ្រងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទប្រកប ដោយនិរន្តរភាពស្រប តាមគោលនយោបាយជាតិស្តីពីទឹកស្អាតនិងអនាម័យ ឆ្នាំ ២០០៣ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹក ស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ២០១៤-២០២៥ ។

លទ្ធផលរំពឹងទុករបស់ ផែនការសកម្មភាពជាតិទីពីរ គឺ៖ នៅឆ្នាំ ២០២៣ប្រជាពលរដ្ឋនៅតំបន់ជនបទទទួលបាន កា ន់ តែច្រើននឹងប្រើប្រាស់ទឹកស្អាត ការរស់នៅស្អាត និងអនាម័យប្រកបដោយសមធម៌ និរន្តរភាព និងសុវត្ថិភាព ដែលស្របតាមចក្ខុវិស័យរបស់វិស័យ និងគោលដៅទី៦ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់កម្ពុជា។ ផែនការសកម្មភាពជាតិ គឺជាផ្នែកចាំបាច់មួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩ - ២០២៣ ដែលត្រូវបានបង្កើតឡើងព្រមពេលជាមួយគ្នាដោយក្រសួងអភិវឌ្ឍន៍ជនបទ ផ្អែកតាមយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ ។

ផែនការសកម្មភាពជាតិទីពីរត្រូវបានបង្កើតឡើងដោយមានកិច្ចសហការរួមគ្នាក្រោមការដឹកនាំរបស់ក្រសួង អភិវឌ្ឍន៍ជនបទ។ ផ្អែកលើលទ្ធផលរំពឹងទុករបស់ ផែនការសកម្មភាពជាតិទីពីរ ផែនការសកម្មភាពខេត្តទីពីរ ត្រូវ បានរៀបចំឡើងក្រោមការដឹកនាំរបស់ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់ អនាម័យនៅជនបទ នៅរាជធានី/ខេត្តទាំង ២៥ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រុមសម្របសម្រួលថ្នាក់ ជាតិ និងអ្នកប្រឹក្សាបច្ចេកទេសជាតិ។ ផែនការសកម្មភាពជាតិទីពីរ និង ផែនការសកម្មភាពខេត្តទីពីរ កសាងបន្តលើ លទ្ធផល និងមេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្ត ផែនការសកម្មភាពជាតិ ១ និង ផែនការសកម្មភាព ខេត្តទីមួយ ឆ្នាំ២០១៤-២០១៨ ។

ចំណុចដៅនៃអត្រាគ្របដណ្តប់ ៩០% ដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០២៣ ត្រូវបានកំណត់សម្រាប់ ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យខ្លួនប្រាណជាមូលដ្ឋាន។ នេះមានន័យថា ត្រូវមានការកើនឡើង ៣១,៣% សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត ១៨,៨% សម្រាប់អនាម័យការរស់នៅស្អាត និង ១២,៩% សម្រាប់អនាម័យ ខ្លួនប្រាណធៀបនឹងទិន្នន័យគោល។ ចំណុចដៅនេះក៏មានន័យផងដែរថាចាំបាច់ត្រូវតែផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ជាមូលដ្ឋានដល់ ៧៩៧.៨៣៩ គ្រួសារ/ខ្នងផ្ទះបន្ថែមទៀត សេវាអនាម័យជាមូលដ្ឋានដល់ ៥១១.៩២៤ គ្រួសារ/ខ្នងផ្ទះ និង សេវាអនាម័យខ្លួនប្រាណជាមូលដ្ឋានដល់ ៣៨០.០០០ គ្រួសារ/ខ្នងផ្ទះ ។ ចំណុចដៅទាបជាង នេះគឺ ៣៣% និង ៣៥% ត្រូវបានឯកភាពគ្នាសម្រាប់សេវាកម្មគ្រប់គ្រងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យប្រកបដោយ សុវត្ថិភាព។

ផែនការសកម្មភាពជាតិទីពីរ ព្យាយាមសម្រេចឱ្យបានលទ្ធផលរំពឹងទុកខាងលើ តាមរយៈធាតុចេញចំនួនបួន៖

I)-ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ/ថ្នាក់ខេត្ត និងអាជ្ញាធរមូលដ្ឋាន បានពង្រឹងសមត្ថភាពដើម្បីរៀបចំផែនការ និងសម្របសម្រួល ស្វែងរកការគាំទ្រសម្រាប់ការវិភាជថវិកាបន្ថែមទៀត និងការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ រួមទាំងស្ថាប័ននានា (សាលារៀន និងគ្រឹះស្ថានថែទាំសុខភាព) និងក្នុងពេលមានគ្រោះអាសន្ន ។

II)-ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម និងតំបន់ដែលប៉ះពាល់ដោយសារធាតុអាសេនិច ទទួលបានកាន់តែច្រើនថែមទទៀតនូវសេវាផ្គត់ផ្គង់ទឹកដែលមានការគ្រប់គ្រងប្រកដោយសុវត្ថិភាព សមធម៌ និងនិរន្តរភាព ។

III)-ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម ទទួលបានកាន់តែច្រើនថែមទៀតនូវសេវាអនាម័យដែលមានការគ្រប់គ្រងប្រកបដោយសុវត្ថិភាព សមធម៌ និងនិរន្តរភាព ។

IV)-ប្រជាពលរដ្ឋនៅជនបទ កែលម្អឥរិយាបថ និងទម្លាប់អនាម័យរបស់ពួកគេ ទាក់ទងនឹង ការសាងសង់និងប្រើប្រាស់បង្គន់អនាម័យ ការបរិភោគនិងការទុកដាក់ទឹកប្រកបដោយសុវត្ថិភាព និងការលាងសម្អាតដៃនឹងសាប៊ូ។

ក្រសួងអភិវឌ្ឍន៍ជនបទ គឺជាស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត ផែនការសកម្មភាពជាតិទីពីរ និងមានគណនេយ្យភាពចំពោះការសម្រេចឱ្យបានលទ្ធផលរំពឹងទុក។ ក្រុមការងារបច្ចេកទេស TWG ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ នឹងធ្វើការត្រួតពិនិត្យលើដំណើរការនេះទាក់ទងនឹងការគ្រប់គ្រងរួមទាំងការសម្របសម្រួលកម្មវិធីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទដើម្បីជៀសវាងបញ្ហាដែលមិនចាំបាច់ និងសកម្មភាពត្រួតគ្នា ព្រមទាំងតាមដានមើលការរីកចម្រើន តាមរយៈការពិនិត្យឡើងវិញប្រចាំត្រីមាស និងប្រចាំឆ្នាំ។ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី -ខេត្ត ក្រុមការងារបច្ចេកទេសថ្នាក់រាជធានី -ខេត្តនឹងដើរតួនាទីស្រដៀងគ្នានៅថ្នាក់ក្រោមជាតិទាក់ទងទៅនឹងការអនុវត្ត ផែនការសកម្មភាព។

# ១. សេចក្តីផ្តើម

## ១.១ សាវតា

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានបង្កើតគោលនយោបាយជាតិស្តីពីទឹកស្អាត និងអនាម័យក្នុងឆ្នាំ ២០០៣។ ទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់វិស័យនេះ គឺថាត្រឹមឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅជនបទទាំងអស់ទទួលបានការផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាពសេវាអនាម័យដែលមានការកែលម្អ និងមានសមត្ថភាពរស់នៅក្នុងបរិស្ថានដែលមានអនាម័យ។

យុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ (RWSSH) ឆ្នាំ២០១១-២០២៥ ដែលក្រោយមកទៀត ត្រូវបានផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផែនការយុទ្ធសាស្ត្រជាតិ (NSP) ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ (RWSSH) ឆ្នាំ២០១៤-២០២៥ មានគោលបំណងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបានទស្សនវិស័យរបស់ខ្លួន។ ផែនការយុទ្ធសាស្ត្រជាតិនេះមានគោលបំណងជាយុទ្ធសាស្ត្រចំនួនប្រាំ៖ (i)កែលម្អសេវាផ្គត់ផ្គង់ទឹក (ii) កែលម្អអនាម័យ (iii) ផ្លាស់ប្តូរឥរិយាបថអនាម័យខ្លួនប្រាណ (iv) ការរៀបចំស្ថាប័ន និង (v) ហិរញ្ញប្បទាន។

យុទ្ធសាស្ត្រជាតិហិរញ្ញប្បទានការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ដោយមានការផ្លាស់ប្តូរបន្ថិចសម្រាប់តំបន់ជនបទ (គឺសម្រេចឱ្យបាន ១០០ % ត្រឹមឆ្នាំ២០២៨) ត្រូវបានបង្កើតឡើងស្របពេលជាមួយគ្នានឹងយុទ្ធសាស្ត្រជាតិនេះ។ ក្រុមការងារបច្ចេកទេសស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ (TWG) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ ដើម្បីធានាការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៃការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះបញ្ហាប្រឈមផ្នែកផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ។ ក្រុមការងារនេះត្រូវបានដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងតំណាងភ្នាក់ងារដៃគូអភិវឌ្ឍន៍ជាសហប្រធាន ដោយមានការប្តូរវេនគ្នាដឹកនាំ។ សមាជិករបស់ក្រុមការងារនេះ គឺតំណាងជាន់ខ្ពស់មកពីក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សំខាន់ៗ។

ដំណាក់កាលទី១ នៃការអនុវត្តយុទ្ធសាស្ត្រជាតិ ត្រូវបានណែនាំដោយផែនការសកម្មភាពជាតិសម្រាប់ឆ្នាំ២០១៤-២០១៨ ដែលត្រូវបានដាក់តម្រូវតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ (NSDP III)។ ផែនការសកម្មភាពថ្នាក់ខេត្តស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០១៨ (PAPs I) ត្រូវបានបង្កើតឡើងនៅក្នុងខេត្តនីមួយៗនៃរាជធានី-ខេត្តទាំង ២៥ ដើម្បីផ្តល់ការណែនាំជាក់លាក់បន្ថែមទៀតសម្រាប់ការអនុវត្តនៅថ្នាក់ក្រោមជាតិ។

ក្រុមការងារបច្ចេកទេសថ្នាក់ខេត្តស្តីពីការផ្គត់ផ្គង់ទឹស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ត្រូវបានបង្កើតចាប់តាំងពីឆ្នាំ២០១៧ ដើម្បីត្រួតពិនិត្យមើលការអនុវត្តផែនការសកម្មភាពថ្នាក់រាជធានី-ខេត្តនៅតាមរាជធានី-ខេត្តនីមួយៗ។

វឌ្ឍនភាពនៃការអនុវត្ត NAP I និង PAPs I ត្រូវបានរាយការណ៍ជូនក្រុមការងារបច្ចេកទេសពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ជាទៀងទាត់ ហើយការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយមួយត្រូវបានធ្វើឡើងនៅក្នុងឆមាសទី១ នៃឆ្នាំ២០១៨។ ការកែលម្អអនាម័យនៅជនបទមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ពោលគឺៈ ចំណុចដៅនៃការគ្របដណ្តប់ ៦០%ត្រឹមឆ្នាំ ២០១៨ត្រូវបានសម្រេចហើយអត្រាគ្របដណ្តប់បានឈានដល់ ៧១,២% ក្នុងឆ្នាំ២០១៧[៤]។ អត្រាបន្ទោបង់ពាសវាលពាសកាលនៅជនបទត្រូវបានកាត់បន្ថយចំនួន ៣១,៥ %[៥] ដែលធ្វើឱ្យប្រទេសកម្ពុជាទទួលបានការទទួលស្គាល់ជាប្រទេសមួយ ក្នុងចំណោមបណ្តាប្រទេសនានាដែលទទួលបានជោគជ័យបំផុត ក្នុងការពន្លឿនការលុបបំបាត់ទម្លាប់ប្រកបដោយគ្រោះថ្នាក់នេះ។ តាមរបាយការណ៍ពីរាជធានី-ខេត្តទាំង ២៥ បានបង្ហាញថាជាមធ្យមគ្រួសារចំនួន ៦៦% មានបង្គន់អនាម័យដែលមានការកែលម្អសម្រាប់ប្រើប្រាស់។ ការកែលម្អសេវាផ្គត់ផ្គង់ទឹកនៅជនបទ មានវឌ្ឍនភាពតិចជាងនេះនៅក្នុងអំឡុងពេល NAP I។

ទោះបីជាមានការសម្រេចបានទាំងនេះក្តី ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ប្រឈមនឹងបញ្ហាចម្បងមួយចំនួន រួមបញ្ចូលទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ។ ទឹកជំនន់និងគ្រោះរាំងស្ងួតអាចបណ្តាលឱ្យមានការរំខាននិងខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យរួមមានប្រព័ន្ធទឹកតាមបំពង់សហគមន៍ ប្រភពទឹក (អណ្តូងនិងស្រះទឹក) បង្គន់អនាម័យ និងបរិក្ខារផ្សេងទៀត។ គ្រោះរាំងស្ងួតក្នុងឆ្នាំ ២០១៦ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ ប្រមាណជា ២,៥លាននាក់[៦]ខណៈដែលគ្រោះទឹកជំនន់ក្នុងឆ្នាំ ២០១៣ បានប៉ះពាល់អណ្តូងទឹកចំនួន ៣៨.៥១៦ អណ្តូង[៧] ដែលបង្កឱ្យមានហានិភ័យផ្នែកសុខភាពទាក់ទងនឹងការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទដែលបណ្តាលមកពីការទទួលបានសេវាការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទដែលបានកាត់បន្ថយ។ ដើម្បីបន្សាំទៅនឹងហានិភ័យទាំងនេះ នវានុវត្តន៍ និងភាពជាដៃគូស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទដែលមានភាពធន់ទៅនឹងអាកាសធាតុនឹងត្រូវបានយកមកធ្វើការពិចារណានៅក្នុង NAP II។

## ១.២ អាទិភាពនៃការអភិវឌ្ឍដែលត្រូវដោះស្រាយ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព ដូចមានចែងក្នុងមុំទី ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ផ្តោតការយកចិត្តទុកដាក់ទៅលើៈ ១) លើកកម្ពស់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ២) ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយនិរន្តរភាព ៣) ពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង ៤) ធានានិរន្តរភាពបរិស្ថាន និងការត្រៀមឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការទទួលបាន ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ត្រូវបានកំណត់ជាអាទិភាពមួយសម្រាប់លើកកម្ពស់ការអភិវឌ្ឍជនបទជាពិសេសនៅក្នុងមុំទី ៤ នៃចតុកោណទី ៤ ដើម្បីជំរុញការអភិវឌ្ឍ និងការអនុវត្តនូវសមាហរណកម្មផែនការគ្រប់គ្រងធនធានទឹកដើម្បីពង្រីកការផ្គត់ផ្គង់ទឹកក្នុងការឆ្លើយតបទៅនឹងតម្រូវការបន្ថយជាអប្បបរមានៃហានិភ័យដែលបណ្តាលដោយគ្រោះរាំងស្ងួត និងទឹកជំនន់ ក៏ដូចជាដើម្បីធានានូវសុវត្ថិភាពទឹកសម្រាប់

[៤] ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៧។

[៥] ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៣ និង ២០១៧។

[៦] របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

[៧] របាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ក្រោយទឹកជំនន់ សម្រាប់ការស្តារឡើងវិញឆ្នាំ ២០១៣

រយៈពេលវែង។

ទោះបីជាមានការរីកចម្រើនក្តី អត្រាគ្របដណ្តប់ទឹកស្អាត និងអនាម័យជនបទមិនគ្រប់គ្រាន់ នៅតែជាកត្តារួមចំណែកចម្បងមួយចំពោះអត្រាមរណភាពកុមារដ៏ខ្ពស់នៅក្នុងប្រទេសកម្ពុជា[៨]។ ជារួមកុមារប្រមាណ ១៣% ក្នុងចំណោមកុមារទាំងអស់ដែលមានអាយុក្រោម ៥ ឆ្នាំ មានជំងឺរាក ហើយ ២% មានជំងឺរាករូសលាយឈាម[៩]។ អត្រាដ៏ខ្ពស់នៃភាពក្រិះក្រិនក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំ (៣២% ក្រិះក្រិន និង ៩% ក្រិះក្រិនធ្ងន់ធ្ងរ[១០]) ក៏បានបង្ហាញពីសារសំខាន់នៃការខ្វះខាតទឹកស្អាត និងកង្វះអនាម័យក្នុងការរស់នៅអនាម័យខ្លួនប្រាណរួមជាមួយនឹងបញ្ហាផ្សេងទៀត ដែលទាក់ទងនឹងអាហារូបត្ថម្ភ និងសុខភាព ប្រកបដោយលក្ខណៈគ្រប់ជ្រុងជ្រោយ និងសមាហរណកម្ម។

ការបង្កើនការទទួលបានសម្ភារ/ប្រព័ន្ធទឹកស្អាត និងអនាម័យនៅតាមសាលារៀន អាចធ្វើឱ្យប្រសើរឡើងនូវសុខភាព វត្តមានការសិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូ ហើយអាចរួមចំណែកដល់លទ្ធផលនៃការអប់រំកាន់តែប្រសើរឡើង។ ទឹកស្អាត និងអនាម័យនៅតាមសាលារៀន មានសារសំខាន់ជាពិសេសសម្រាប់កុមារី និងស្ត្រីវ័យក្មេង ដូចជា ការផ្តល់ភាពឯកជនសម្រាប់ការគ្រប់គ្រងអនាម័យពេលមានរដូវ។ សិស្សានុសិស្សត្រូវបានគេតម្រូវឱ្យចាប់ផ្តើមរៀនអំពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទតាមរយៈកម្មវិធីសិក្សាក្នុងសាលា។ បន្ទាប់មកសិស្ស និងក្រុមគ្រួសាររបស់ពួកគេ អាចចាប់ផ្តើមយល់ពីទំនាក់ទំនងរវាងទឹក សុខភាព ការរស់នៅស្អាត អនាម័យ និងអាហារូបត្ថម្ភ[១១]។

ការទទួលបានទឹកដែលមានសុវត្ថិភាព បង្គន់អនាម័យសមស្រប ដែលធានាបាននូវការប្រើប្រាស់សម្រាប់កុមារពិការ និងសម្ភារ/ទីកន្លែងលាងសម្អាតដៃនៅក្នុងសាលារៀននៅតែជាបញ្ហាប្រឈមមួយ។ ជារួមសាលារៀននៅទីជនបទតិចជាង ៥០ % មានសម្ភាររូបវន្តទាំងនេះ (facilities) សម្រាប់ប្រើប្រាស់[១២]។

សម្ភាររូបវន្តទឹកស្អាត និងអនាម័យនៅក្នុងមណ្ឌលសុខភាព មានសារសំខាន់ជាសារវ័ន្តសម្រាប់កែលម្អគុណភាពនៅក្នុងបរិបទនៃការគ្របដណ្តប់លើសុខភាពជាសកល។ មានតែ ៣៦ % នៃមណ្ឌលសុខភាពប៉ុណ្ណោះ[១៣] ដែលមានសម្ភាររូបវន្ត/កន្លែងអនាម័យជាមូលដ្ឋាន (basic sanitation facilities) ខណៈពេលដែលការទទួលបានការផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន បានឈានដល់ ៩០%[១៤] មណ្ឌលសុខភាពជិត ៥០% ខ្វះទឹកផឹកដែលមានសុវត្ថិភាពជាពិសេសសម្រាប់អតិថិជន ហើយមានការខ្វះខាតទឹកនៅក្នុងរដូវប្រាំង[១៥]។

[៨] ការវិភាគស្ថានភាពស្ត្រីនិងកុមារនៅក្នុងប្រទេសកម្ពុជា ដោយអង្គការយូនីសេហ្វ ឆ្នាំ ២០១៧។

[៩] Ibid.

[១០] ibid.

[១១] SDG 6, របាយការណ៍សំយោគស្តីពីទឹក និងអនាម័យ ឆ្នាំ ២០១៨។

[១២] Washdata.org, ផ្អែកលើ on EMIS 2016/2017.

[១៣] ក្រសួងសុខាភិបាល (២០១៦) ផែនការយុទ្ធសាស្ត្រសុខាភិបាលទីបី ឆ្នាំ ២០១៦-២០២០។

[១៤] Ibid.

[១៥] ការវាយតម្លៃ ធ្វើឡើងដោយវិទ្យាស្ថានជាតិសុខភាពសាធារណ: ដោយមានការគាំទ្រពី WaterAid, WHO និង UNICEF ឆ្នាំ ២០១៥។

## ១.៣ ដំណើរការនៃការបង្កើត NAP II

ក្រសួងអភិវឌ្ឍន៍ជនបទ បានចាប់ផ្តើមដឹកនាំកិច្ចសហការ ដើម្បីរៀបចំផែនការសកម្មភាពស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ឆ្នាំ ២០១៩-២០២៣ (RWSSH NAP II) និង PAPs II កាលពីឆមាសទីពីរនៃឆ្នាំ ២០១៨។ ពោលគឺ ភ្លាមៗបន្ទាប់ពីបានបញ្ចប់ការពិនិត្យឡើងវិញលើ NAP I និង PAPs I ។ ដៃគូនៃវិស័យនេះ បានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការដែលដឹកនាំដោយរាជរដ្ឋាភិបាលនេះ ក្នុងគោលបំណងផ្តល់ឱកាសដល់ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ ដំណើរការនេះមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ឃុំ រួមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិផងដែរ ។

ខាងក្រោមនេះគឺជាជំហានសំខាន់ៗដែលត្រូវបានអនុវត្តនៅក្នុងការរៀបចំ NAP II:

- ការរៀបចំក្របខណ្ឌលទ្ធផលនៃ NAP II
- ការរៀបចំ PAPs II នៅក្នុងខេត្តនីមួយៗក្នុងចំណោមរាជធានី-ខេត្តទាំង ២៥ ក្រោមការដឹកនាំរបស់ក្រុមការងារបច្ចេកទេសថ្នាក់រាជធានី-ខេត្ត ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រុមការងារថ្នាក់ជាតិ និងទីប្រឹក្សាជាតិ។
- សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ
- ការដាក់បញ្ចូលគ្នានូវ PAPs II និងការបញ្ចប់ជាចុងក្រោយនៃ NAP II
- ការពិនិត្យឡើងវិញចុងក្រោយដោយ TWG-RWSSH

## ១.៤ រចនាសម្ព័ន្ធ NAP II

ការកសាងបន្តលើលទ្ធផល និងមេរៀនដែលទទួលបានពីការអនុវត្តកម្មវិធី NAP I កន្លងមក រួមបញ្ចូលទាំងផលប៉ះពាល់នៃអាកាសធាតុផងដែរ NAP II និង PAPs II ត្រូវបានបង្ហាញកាន់តែច្បាស់លាស់ថែមទៀត។ រចនាសម្ព័ន្ធនៃឯកសារ NAP II អនុវត្តតាមការណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងគោលការណ៍ណែនាំសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ដែលចេញដោយក្រសួងផែនការ ក្នុងខែកញ្ញា ឆ្នាំ២០១៨ ។

## រូបភាពបង្ហាញពីសមាសភាគសំខាន់ៗនៃ NAP

### រូបភាពទី ១: រចនាសម្ព័ន្ធនៃ NAP II- RWSSH



# ២. ការវិភាគស្ថានភាព

## ២.១ ស្ថានភាពបច្ចុប្បន្នរបស់វិស័យ

នៅក្នុង ឆ្នាំ ២០១៤-២០១៨ នៃ NAP I វិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងជួបប្រទះបញ្ហាប្រឈមមួយចំនួនផងដែរ។ មានវឌ្ឍនភាពយ៉ាងរហ័សក្នុងការកែលម្អអនាម័យនៅជនបទ ដែលលើសពីចំណុចដៅ ៦០ % នៃការទទួលបានសេវាអនាម័យដែលមានការកែលម្អ ចំនួន ១១,២ % ក្នុងឆ្នាំ ២០១៧[១៦]។ ការបន្ទោបង់ពាសវាលពាសកាល បានថយចុះចំនួន ៣១,៥ % ហើយភូមិសរុបចំនួន ១.៧៨៩ ភូមិ ឃុំចំនួន ៦៧ និង ស្រុកចំនួន ២ សម្រេចបានស្ថានភាពគ្មានការបន្ទោបង់ពាសវាលពាសកាល (ODF)[១៧]។

ការផ្គត់ផ្គង់ទឹកនៅជនបទបានកើនឡើង ១២,១% ចាប់តាំងពីឆ្នាំ ២០១៣ ប៉ុន្តែនៅមានគម្លាត ១,៣% ពីគោលដៅ ៦០% គិតត្រឹមឆ្នាំ ២០១៨[១៨]។ ចំណុចដៅសម្រាប់ការលាងសម្អាតដៃនឹងសាប៊ូ[១៩] ត្រូវបានសម្រេច ប៉ុន្តែចំណុចដៅសម្រាប់ការធ្វើប្រព្រឹត្តិកម្មទឹកផឹក មិនត្រូវបានសម្រេចឡើយ (សូមមើលរូបភាពទី ២)។

រូបភាពទី ២: ស្ថានភាពសូចនាករលទ្ធផលរំពឹងទុក ឆ្នាំ ២០១៤-២០១៨




### ការពិនិត្យឡើងវិញលើ NAP I បានបង្ហាញពីសមិទ្ធផលទាំងឡាយដូចខាងក្រោម៖

- ភាពជាអ្នកដឹកនាំបានស្ទែងចេញឡើងនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើតក្រុមការងារបច្ចេកទេសថ្នាក់ខេត្តស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ដើម្បីត្រួតពិនិត្យមើលការអនុវត្ត PAPs ឆ្នាំ ២០១៤-២០១៨

[១៦] ការអង្កេតសង្គមកិច្ចសេដ្ឋកិច្ច (CSES) ២០១៧ ។

[១៧] RWSSH MIS, 2018.

[១៨] Ibid.

[១៩] ក្រ.អ.ជ.ប (២០១៦) ការអង្កេតចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត (KAP) ។

- ភាពប្រសើរឡើងជាច្រើននៃបរិយាកាសអំណោយផលសម្រាប់អនាម័យ ដែលបានលើកទឹកចិត្តដល់ការអនុវត្តវិធីសាស្ត្រថ្មីៗចំពោះការលើកកម្ពស់អនាម័យនៅជនបទ។
- ការចូលរួមកាន់តែខ្លាំងក្លាពីសំណាក់អ្នកផ្តល់សេវា តាមរយៈគំនិតផ្តួចផ្តើមផ្សព្វផ្សាយអនាម័យ ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថា ជាកត្តារួមចំណែកដ៏សំខាន់មួយចំពោះកំណើនអត្រាគ្របដណ្តប់អនាម័យ។
- ការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទ (MIS) ការបង្កើតវេទិកាសម្របសម្រួលបច្ចេកទេស ដូចជា អនុក្រុមការងារសម្រាប់អនាម័យនៅជនបទ (RuSH) ការផ្គត់ផ្គង់ទឹកស្អាត(WS) អនាម័យនៅក្នុងបរិស្ថានប្រឈម(SCE) ទឹកស្អាត-អនាម័យ និងអាហារូបត្ថម្ភ (WASH-Nutrition) ដើម្បីធានាការសម្របសម្រួលនិងសុខដុមនីយកម្មកាន់តែប្រសើរ ។

# ២.២ កត្តាប្រឈម

### ទោះបីជាមានវឌ្ឍនភាពយ៉ាងនេះក្តី កត្តាប្រឈមនៅតែមាន ជាពិសេស៖

វិសមភាពនៃសេវា ដែលស្តែងចេញឱ្យឃើញតាមរយៈភាពខុសគ្នានៃអត្រាសេវា រវាងតំបន់ជនបទ ទីប្រជុំជននិងក្នុងចំណោមកម្រិតជីវភាពទាំង៥ ដូចមានបង្ហាញខាងក្រោម[២០]។

រូបភាពទី ៣: វិសមភាពការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ




[២០] https://washdata.org/data

### រូបភាពទី ៣: វិសមភាពការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ




### សម្ភារបរិក្ខារូបវន្តទឹកស្អាត និងអនាម័យមិនគ្រប់គ្រាន់នៅសាលារៀន និងមណ្ឌលសុខភាព

ដូចបង្ហាញក្នុងតារាងទី១ ស្រាប់ ៨៨ % សាលារៀននៅជនបទ មានសេវាទឹកស្អាតមានកម្រិត (ដែលត្រូវបានកំណត់និយមន័យថាជាប្រភពដែលមានការកែលម្អ មានទឹកសម្រាប់ប្រើ) ៣៨ %មានសេវាអនាម័យជាមូលដ្ឋាន (ត្រូវបានកំណត់និយមន័យជាបន្ទប់ទឹកសម្រាប់ភេទតែមួយគត់ដែលមានការកែលម្អ ដែលអាចប្រើបាន) និង ៣៩ % មានសេវាអនាម័យខ្លួនប្រាណជាមូលដ្ឋាន (ត្រូវបានកំណត់ជាកន្លែងលាងសម្អាតដៃដែលមានទឹក និងសាប៊ូសម្រាប់ប្រើ)។

**តារាងទី 1: ទឹកស្អាត និងអនាម័យនៅក្នុងសាលារៀន**

| | ទឹកស្អាត សេវាមានកម្រិត | អនាម័យ ជាមូលដ្ឋាន (មានការកែលម្អអាចប្រើបាន និងបែងចែកតាមភេទ) | អនាម័យខ្លួនប្រាណ សេវាជាមូលដ្ឋាន (ទីកន្លែងលាងសម្អាតដៃ ដែលមានទឹក និងសាប៊ូ) |
|---|---|---|---|
| ថ្នាក់ជាតិ | ៨៩ | ៣៩ | ៤១ |
| ទីប្រជុំជន | ៨៩ | ៤៨ | ៥០ |
| ជនបទ | ៨៨ | ៣៨ | ៣៩ |
| មត្តេយ្យសិក្សា | ៣៣ | ១២ | ២៧ |
| បឋមសិក្សា | ៦១ | ៤៨ | ៤៩ |
| មធ្យមសិក្សា | ៨៧ | ៦៧ | ៤០ |

ប្រភព៖ washdata.org, ផ្អែកលើជំរឿន ឆ្នាំ២០១៩ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងវិស័យអប់រំ (EMIS) ២០១៦ / ២០១៧

ជារួម ៩០% នៃមណ្ឌលសុខភាពបានរាយការណ៍ឱ្យដឹងថា ការទទួលបានការផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋានក្នុងខណៈដែលមណ្ឌលសុខភាពមានតែ ៣៧ % ប៉ុណ្ណោះទទួលបានសេវាអនាម័យជាមូលដ្ឋាន[២១]។ ការវាយតម្លៃឆ្នាំ២០១៥ មួយដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ និងក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការ WaterAid អង្គការសុខភាពពិភពលោក និងអង្គការយូនីសេហ្វ នៅក្នុងមណ្ឌលសុខភាព ក្នុងខេត្តចំនួន ៥ បានបង្ហាញពីសេវាទឹកស្អាតនិងអនាម័យមិនគ្រប់គ្រាន់៖

- ទោះបីជាមានការផ្គត់ផ្គង់ទឹកស្អាតក្តី ៩៩% នៃ មណ្ឌលសុខភាព នៅតែខ្វះខាតទឹកស្អាតសម្រាប់ផឹកជាពិសេស សម្រាប់អតិថិជន ហើយមានការខ្វះខាតទឹកនៅរដូវប្រាំងផងដែរ។
- ៦% នៃមណ្ឌលសុខភាព ពឹងផ្អែកលើប្រភពទឹកដែលមិនមានការកែលម្អ/ប្រភពទឹកចំហ។
- មានបង្គន់ដែលបានកែលម្អ ប៉ុន្តែមិនបានបំពេញតាមតម្រូវការរបស់មនុស្សដែលមានពិការភាព និងស្ត្រីមានផ្ទៃពោះនោះទេ។ មិនមានបង្គន់អនាម័យគ្រប់គ្រាន់ ដែលមានសម្ភារគ្រប់គ្រងអនាម័យពេលមានរដូវ ដែលរៀបចំឡើងសម្រាប់ស្ត្រី និងកុមារីនោះទេ។
- សម្ភារ/ឧបករណ៍សម្រាប់ការលាងសម្អាតដៃមានមិនគ្រប់គ្រាន់នៅកន្លែងថែទាំអ្នកជំងឺផ្ទាល់ និងនៅក្នុងបង្គន់។

## ហិរញ្ញប្បទានមិនគ្រប់គ្រាន់

ហិរញ្ញប្បទានសម្រាប់ ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ត្រូវបានរាយការណ៍ឱ្យដឹងថាមានមិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការដែលកំណត់សម្រាប់ទូទាំងប្រទេស។ នៅក្នុងឆ្នាំ ២០១៥ ការវាយតម្លៃលើការផ្តល់សេវាសម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទនៅកម្ពុជា ត្រូវបានធ្វើឡើងដោយមានការចូលរួមពីស្ថាប័នជាច្រើន រួមទាំងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងក្រោមការណែនាំពីកម្មវិធីទឹកស្អាត និងអនាម័យរបស់ធនាគារពិភពលោក។

ការវាយតម្លៃលើការផ្តល់សេវានេះបានបង្ហាញថា ដើម្បីសម្រេចបានអត្រាគ្របដណ្តប់ ១០០% នៅឆ្នាំ ២០២៥ប្រជាពលរដ្ឋប្រហែល ៣០២.០០០ នាក់ក្នុងមួយឆ្នាំ ត្រូវតែទទួលបានប្រភពទឹកដែលមានការកែលម្អ។ នេះមានន័យថា ត្រូវមានការវិនិយោគទុនជាមធ្យមចំនួន ៣២ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ រួមទាំងការវិនិយោគថ្មីចំនួន ៦,៤ លានដុល្លារអាមេរិក ដើម្បីពង្រីកការទទួលបានសេវា និង ២៥,៤ លានដុល្លារអាមេរិក ដើម្បីប្តូរជំនួសសម្ភាររូបវន្ត (facilities) ដែលមានស្រាប់។

ការធានាថាប្រជាពលរដ្ឋ ប្រហែល ៦៥៨.០០០ នាក់ ទទួលបានសេវាអនាម័យដែលមានការកែលម្អត្រូវការចំណាយដើមទុនចំនួន ៣២,៥ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដែលក្នុងនោះគេរំពឹងថា ទឹកប្រាក់ ៣,៥លានដុល្លារអាមេរិក នឹងបានមកពីប្រភពសាធារណៈ។ ការចំណាយនេះ នឹងគាំទ្រដល់ការឧបត្ថម្ភធនផ្នែករឹងសម្រាប់គ្រួសារក្រីក្រ ដោយហេតុថា បង្គន់អនាម័យភាគច្រើននឹងត្រូវបានសាងសង់ឡើងដោយប្រើថវិកាផ្ទាល់របស់គ្រួសារដូចដែលបានកំណត់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រនេះ។ គំរូគណនាចំណាយ ដែលអនុវត្តនៅក្នុងការវាយតម្លៃលើការផ្តល់សេវានេះ ដើម្បីវាយតម្លៃភាពគ្រប់គ្រាន់នៃការវិនិយោគនាពេលអនាគតនៅក្នុងវិស័យនេះ បង្ហាញ

[២១] ក្រសួងសុខាភិបាល (២០១៦) ផែនការយុទ្ធសាស្ត្រសុខាភិបាលទីបី ឆ្នាំ ២០១៦-២០២០ ។

ថាមានឱនភាពប្រចាំឆ្នាំចំនួន ២៩ % សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ និងឱនភាពប្រចាំឆ្នាំចំនួន ៥,៧ % សម្រាប់អនាម័យនៅជនបទ។ ហិរញ្ញប្បទានមិនគ្រប់គ្រាន់ក៏ជាឧបសគ្គចម្បង សម្រាប់ដោះស្រាយភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ការបញ្ចូលភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងការអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទនឹងត្រូវការចំណាយច្រើនបន្ថែមទៀត។

## សមត្ថភាពស្ថាប័នមិនគ្រប់គ្រាន់ និងមិនស្មើគ្នា

ការពិនិត្យឡើងវិញលើ NAP I បានបង្ហាញពីសមិទ្ធផលនៅមានកម្រិតក្នុងការអភិវឌ្ឍសមត្ថភាពរួមទាំងការរៀបចំផែនការ និងការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈនៅថ្នាក់ក្រោមជាតិ និងការចូលរួមរបស់វិស័យឯកជន។ ដំណើរការវិមជ្ឈការដើម្បីកែលម្អការផ្តល់សេវាមិនទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយទេ។ ការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយមិនត្រូវបានគេដាក់បញ្ចូលទៅក្នុងការតាក់តែង និងការគ្រប់គ្រងផែនការនេះឡើយ។

ភាពចាំបាច់នៃការសម្របសម្រួលរឹងមាំមិនទាន់ត្រូវបានបំពេញនៅឡើយទេ។ វិស័យនេះមានការពាក់ព័ន្ធនឹងក្រសួងនានារបស់រាជរដ្ឋាភិបាល ដែលមានតួនាទីនៅក្នុងវិស័យទឹក និងអនាម័យ រួមជាមួយម្ចាស់ជំនួយអង្គការមិនមែនរដ្ឋាភិបាល និងប្រតិបត្តិករឯកជនជាច្រើនទៀត។ ការចូលរួមពីវិស័យពាក់ព័ន្ធនៅក្នុងការដាក់បញ្ចូល WASH ទៅក្នុងកម្មវិធីអភិវឌ្ឍន៍ដែលពាក់ព័ន្ធនានានៅមានកម្រិត។ ទោះបីជាមានការសម្របសម្រួលល្អរវាងអ្នកផ្តល់ជំនួយកន្លងមក និងរាជរដ្ឋាភិបាលក្តី ប៉ុន្តែម្ចាស់ជំនួយដែលទើបតែចូលមកថ្មី ដែលកំពុងតែផ្តល់ការគាំទ្រ និងមានសារសំខាន់កាន់តែច្រើនជាងបន្តិចម្តងៗ នៅមិនទាន់ត្រូវបានដាក់បញ្ចូលទៅក្នុងយន្តការសម្របសម្រួលដែលមានស្រាប់នេះនៅឡើយទេ។ វិស័យឯកជនកំពុងតែដើរតួនាទីកាន់តែច្រើនឡើងយ៉ាងឆាប់រហ័ស នៅក្នុងការផ្តល់សេវាទឹកស្អាតនៅជនបទ (តាមរយៈប្រព័ន្ធទឹកតាមបំពង់ និងស្ថានីយ៍ផលិតទឹកប៊ីដុង (Water Kiosks)។ តួអង្គវិស័យឯកជនទាំងនេះស្ថិតនៅក្រោមអាណត្តិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែការសម្របសម្រួល និងការធ្វើផែនការរួមគ្នាជាមួយក្រសួងអភិវឌ្ឍន៍ជនបទនៅមានកម្រិត ដែលជាហេតុធ្វើឱ្យការប្រើប្រាស់ធនធានមិនមានប្រសិទ្ធភាព។

គោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធ មិនទាន់ត្រូវបានរៀបចំឡើងនៅឡើយ សម្រាប់អន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតឡើង និងបញ្ហាដែលមានជាយូរយាមកហើយ ដូចជាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់សហគមន៍ និងគ្រប់គ្រងដោយសហគមន៍ផ្ទាល់ ការគ្រប់គ្រងកាកសំណល់លាមក និងភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធ ទឹកស្អាត និងអនាម័យ (WASH) ។

## ប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃមិនគ្រប់គ្រាន់

តម្រូវការសម្រាប់ការកែលម្អការត្រួតពិនិត្យ តាមដានវិស័យនេះ ត្រូវបានទទួលស្គាល់នៅក្នុងឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រនានា និងការពិនិត្យឡើងវិញទៅលើវិស័យនេះ។ WASH-MIS ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៧ ហើយបានចាប់ផ្តើមប្រមូលទិន្នន័យ និងកំណត់សូចនាករសំខាន់ៗចំនួន ៦ ដែលភាគច្រើនទាក់ទងនឹងការកែលម្អផ្នែកអនាម័យ (sanitation)។ ប្រព័ន្ធត្រួតពិនិត្យ តាមដានតាមវិស័យ ដែលរាយ

ការណ៍អំពីការទទួលបាន និងការប្រើប្រាស់សេវា គុណភាពសេវា និរន្តរភាព និងសមធម៌ នៅមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ។ ទិន្នន័យ និងព័ត៌មានដែលបង្កើតឡើងតាមរយៈការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ មិនទាន់ត្រូវបានបោះពុម្ពផ្សាយ ហើយក៏មិនទាន់បានដាក់ក្នុងគេហទំព័ររបស់ក្រសួងដែរ។

## វិសមភាពយេនឌ័រ

យេនឌ័រ និងទិដ្ឋភាពផ្សេងទៀតនៃការបញ្ជ្រាបបរិយាប័ន្នសង្គម ត្រូវបានអនុវត្តនៅក្នុងគំនិតផ្តួចផ្តើមរបស់វិស័យផ្សេងៗ ជាពិសេសគម្រោងដែលគាំទ្រដោយដៃគូ។ គំនិតផ្តួចផ្តើមទាំងនេះ មិនទាន់ត្រូវបានធ្វើស្ថាប័ននីយកម្មនៅឡើយទេ។ ការលើកកម្ពស់ស្ត្រីឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការកែលម្អ RWSSH រួមទាំងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិនៅគ្រប់កម្រិតថ្នាក់ត្រូវតែបន្តអនុវត្ត។ ការដាក់បញ្ចូលការគ្រប់គ្រងអនាម័យពេលមករដូវទៅក្នុងកិច្ចអន្តរាគមន៍របស់ RWSSH ទើបតែចាប់ផ្តើមនៅដំណាក់កាលដំបូង ហើយត្រូវការ ការពង្រឹង និងពង្រីកបន្ថែមទៀត។

## ភាពធន់នឹងអាកាសធាតុ

ធនធាន និងហេដ្ឋារចនាសម្ព័ន្ធទឹក គឺជាវិស័យមួយដែលងាយរងគ្រោះបំផុតទៅនឹងផលប៉ះពាល់នៃព្រឹត្តិការណ៍អាកាសធាតុ។ ដោយសារកម្រិតទាបនៃភាពធន់ចំពោះអាកាសធាតុ គ្រួសារក្រីក្រនៅជនបទកាន់តែប្រឈមនឹងហានិភ័យអាកាសធាតុតាមរដូវកាលកាន់តែច្រើនថែមទៀត៖

- ប្រជាពលរដ្ឋនៅតំបន់ជនបទ ទទួលរងការធ្លាក់ចុះចំនួន ២២% នូវប្រភពទឹកដែលមានការកែលម្អទាំងក្នុងរដូវវស្សា និងរដូវប្រាំង ប្រៀបធៀបទៅនឹងការធ្លាក់ចុះ ២% នៅក្នុងតំបន់ទីប្រជុំជនក្នុងរយៈពេលដូចគ្នា[២២]។
- គ្រួសារនៅតំបន់ជនបទដែលក្រីក្របំផុត មានការថយចុះ ២០% ធៀបនឹងការធ្លាក់ចុះ ១១% ក្នុងចំណោមគ្រួសារដែលមានជីវភាពធូរធារបំផុតនៅក្នុងតំបន់ជនបទ[២៣]។
- ៥២ % នៃមណ្ឌលសុខភាព បានរាយការណ៍ថា ប្រភពទឹកដែលពួកគេមាន មិនអាចផ្តល់ទឹកគ្រប់គ្រាន់ពេញមួយឆ្នាំសម្រាប់ប្រើប្រាស់គ្រប់គោលបំណងទាំងអស់ឡើយ (ដូចជា សម្រាប់ផឹក ការធ្វើម្ហូបអាហារ អនាម័យខ្លួនប្រាណ សកម្មភាពផ្នែកវេជ្ជសាស្ត្រ ការសម្អាត និងបោកគក់)[២៤]។
- ១៧,២% នៃឃុំនៅក្នុងប្រទេសកម្ពុជា (ស្មើនឹង ២៧៩ ឃុំ) ងាយរងគ្រោះ “យ៉ាងខ្លាំង” ហើយជាង ៣១,៥ % (ស្មើនឹង ៥១២ ឃុំ) ងាយរងគ្រោះ “ខ្លាំង” ទៅនឹងមុខសញ្ញាគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុ។[២៥]

[២២] ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ ២០១៤។
[២៣] ក្រសួងសុខាភិបាល (២០១៦) ផែនការយុទ្ធសាស្ត្រសុខាភិបាលទីបី ឆ្នាំ ២០១៦-២០២០ ។
[២៤] វិទ្យាស្ថានជាតិសុខភាពសាធារណៈកម្ពុជា សហការជាមួយនាយកដ្ឋានសេវាមន្ទីរពេទ្យ, UNICEF, WaterAid និង WHO (ឆ្នាំ២០១៧) ការវាយតម្លៃលើទឹកស្អាត សុខភាព និងអនាម័យ នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈនៅក្នុងខេត្តចំនួន ៥ ក្នុងប្រទេសកម្ពុជា។
[២៥] ផែនការយុទ្ធសាស្ត្ររបស់កម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុ (២០១៤-២០២៣) ។

ការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងការកើនឡើងសីតុណ្ហភាព និងហានិភ័យនៃហេតុការណ៍ធាតុអាកាសធ្ងន់ធ្ងរគឺជាការគំរាមកំហែងចម្បងដល់ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យជនបទ។ វិស័យនេះទទួលស្គាល់ភាពងាយរងគ្រោះខ្ពស់ទៅនឹងគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ខណៈពេលដែលសមត្ថភាពជាតិ និងសហគមន៍ក្នុងការឆ្លើយតបទៅនឹងឧប្បត្តិហេតុទាំងនេះនៅមានកម្រិត។ កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើននូវភាពធន់របស់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យត្រូវបានធ្វើឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍សំខាន់ៗ ដែលធ្វើការលើវិស័យទឹកស្អាត និងអនាម័យនៅកម្ពុជា។ ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈគម្រោងដែលគាំទ្រថ្មីៗនេះ បានធ្វើការវិភាគជម្រើសបច្ចេកទេសសមស្រប និងផែនការសុវត្ថិភាពទឹក និងអនាម័យ ដែលដាក់បញ្ចូលភាពបន្សុំាការប្រែប្រួលអាកាសធាតុ និងវិធានការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងការអនុវត្ត និងគំនូសប្លង់បច្ចេកទេសរបស់គម្រោង ដែលផ្តល់ឱ្យនូវមូលដ្ឋានសំខាន់សម្រាប់ការអភិវឌ្ឍ និងការពង្រីកវិសាលភាពនាពេលអនាគត។

# ៣. ទិសដៅជាយុទ្ធសាស្ត្ររបស់វិស័យ

## ៣.១ ទិសដៅជាយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រជាតិស្តីពី RWSSH ដែលត្រូវបានផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០១៤ មានគោលបំណងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបានចក្ខុវិស័យនៃការគ្របដណ្តប់សេវា ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទជាសកលរបស់វិស័យនេះ។ មូលហេតុចម្បងនៃការបង្កើត NAP-RWSSH គឺដើម្បីជួយសម្រួលដល់វឌ្ឍនភាពកាន់តែឆាប់រហ័សនៅក្នុងវិស័យនេះ។ ជាការបន្តបន្ថែមពីលើ NAP I (២០១៤-២០១៨) NAP II (២០១៩-២០២៣) ត្រូវបានបង្កើតឡើងដោយផ្អែកលើការណែនាំជាយុទ្ធសាស្ត្ររបស់ផែនការទាំងឡាយដូចខាងក្រោម៖

### I. ផែនការយុទ្ធសាស្ត្រជាតិស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ (**RWSSH**) ឆ្នាំ ២០១៤-២០២៥

ផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ (RWSSH) ឆ្នាំ ២០១៤-២០២៥បានកំណត់ចំណុចដៅនៃការទទួលបានជាសកល និងដាក់ចេញសកម្មភាព និងគោលការណ៍ជាយុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវចំណុចដៅទាំងនេះ។

### II. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទកំណត់សសរស្តម្ភចំនួន ៤ សំដៅកែលម្អគុណភាពនៃជីវភាព និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជានៅតំបន់ជនបទ។ ផែនការនេះស្របគ្នាជាមួយអាទិភាពមួយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលមានគោលបំណង *"លើកកម្ពស់ការអភិវឌ្ឍជនបទឱ្យកាន់តែមានភាពរស់រវើកថែមទៀត ដោយធ្វើការវិនិយោគបន្ថែមទៀតទៅលើផ្លូវជនបទ ប្រព័ន្ធស្រោចស្រពខ្នាតតូចពង្រីកការគ្របដណ្តប់ការផ្គត់ផ្គង់អគ្គិសនី និងការទទួលបានទឹកស្អាត កែលម្អអនាម័យ" ការរៀបចំភូមិនិងលំនៅដ្ឋាន ក៏ដូចជាការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។*

កម្មវិធីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ (RWSSH) បានគ្របដណ្តប់លើការទទួលបានកាន់តែច្រើនថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធ WASH ជួយសហគមន៍ឱ្យរស់នៅក្នុងបរិស្ថាន ODF និងអនុវត្តឥរិយាបថអនាម័យសំខាន់ៗ។ ភាពជាដៃគូរបស់កម្មវិធីនេះជាមួយវិស័យឯកជននៅក្នុងការកែលម្អការផ្គត់ផ្គង់ទឹក ការលើកកម្ពស់សហគ្រិនដែលផ្គត់ផ្គង់សម្ភារអនាម័យ ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពគឺទាក់ទងនឹងសសរស្តម្ភទាំង ៤ នេះ។

### III. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ( CSDG)

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយកំពុងស្ថិតនៅក្នុងដំណើរការមូលដ្ឋាននីយកម្មគោលដៅទាំងនេះទៅក្នុង CSDGs របស់កម្ពុជា។ ផែនការសកម្មភាព (NAP II) នឹងរួមចំណែកដោយផ្ទាល់ដល់ការសម្រេចបានចំណុចដៅនៃ CSDG របស់កម្ពុជា ។

### តារាងទី ២: គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា

| គោលដៅទី ៦៖ ធានាការផ្គត់ផ្គង់ ការគ្រប់គ្រងទឹក និងអនាម័យប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា | | |
|---|---|---|
| ស្ថាប័នទទួលខុសត្រូវ | ចំណុចដៅ | សូចនាករ |
| | ៦.១: ត្រឹមឆ្នាំ ២០៣០ សម្រេចឱ្យបានការទទួលបាន ជាសកល និងប្រកបដោយសមធម៌នូវទឹកសម្រាប់ផឹក ដែលមានសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា | ៦.១.១.២: សមាមាត្រប្រជាពលរដ្ឋនៅជនបទដែលប្រើសេវាផ្គត់ផ្គង់ទឹកត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព |
| | | ៦.១.១.៣ សមាមាត្រប្រជាពលរដ្ឋនៅជនបទដែលប្រើសេវាប្រភពទឹកសម្រាប់ផឹកជាមូលដ្ឋាន |
| | ៦.២: ត្រឹមឆ្នាំ ២០៣០ សម្រេចឱ្យបានការទទួលបានអនាម័យ(សុខភាព) និងអនាម័យខ្លួនប្រាណឱ្យបានគ្រប់គ្រាន់ និងប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា និងបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល យកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រី/ក្មេងស្រីនិងជនងាយគ្រោះ | ៦.២.១ សមាមាត្រប្រជាពលរដ្ឋដែលប្រើសេវាអនាម័យ (សុខភាព) ដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព រួមទាំងកន្លែងលាងសម្អាតដៃដែលមានសាប៊ូនិងទឹក |
| | | ៦.២.១.១ សមាមាត្រប្រជាពលរដ្ឋនៅជនបទដែលប្រើសេវាអនាម័យដែលមានការកែលម្អជាមូលដ្ឋាន |
| | | ៦.២.១.២ សមាមាត្រគ្រួសារ/ខ្នងផ្ទះនៅជនបទ ដែលមានកន្លែងលាងសម្អាតដៃដែលមានសាប៊ូនិងទឹក |

### RWSSH NAP/PAPs II នឹងរួមចំណែកដល់ការសម្រេចបានចំណុចដៅនៃ CSDG របស់កម្ពុជា ដូចខាងក្រោម៖

| ស្ថាប័នទទួលខុសត្រូវ | ចំណុចដៅ | សូចនាករ |
|---|---|---|
| MoH, CARD, MRD | ២.២. ត្រឹមឆ្នាំ ២០៣០ បញ្ចប់រាល់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំងការសម្រេចបានត្រឹមឆ្នាំ ២០២៥ នូវចំណុចដៅដែលបានឯកភាពជាអន្តរជាតិ សម្រាប់ភាពក្រិះក្រិន និង ស្គមស្គាំងក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំនិងដោះស្រាយតម្រូវការផ្នែកអាហារូបត្ថម្ភរបស់ក្មេងស្រីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ និង ស្ត្រីកំពុងបំបៅកូនដោយទឹកដោះ និងមនុស្សចាស់ | ២.២.១ ប្រេវ៉ាឡង់នៃភាពក្រិះក្រិនក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំ |
| | | ២.២.២ ប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំ |
| ក្រសួងសុខាភិបាល (MoH) | ៣.១០. ត្រឹមឆ្នាំ ២០៣០ កាត់បន្ថយករណីស្លាប់ នឹងជំងឺដោយសារជាតិគីមីគ្រោះថ្នាក់ ការបំពុលភាពកខ្វក់នៃខ្យល់ ទឹក និងដី | ៣.១០.១ %នៃគ្រឹះស្ថានថែទាំសុខភាពសាធារណ: ដែលមានការផ្គត់ផ្គង់ទឹកជាមូលដ្ឋាន |
| | | ៣.១០.២ %នៃគ្រឹះស្ថានថែទាំសុខភាព |

| ស្ថាប័ន ទទួលខុសត្រូវ | ចំណុចដៅ | សូចនាករ |
|---|---|---|
| ក្រសួង អភិវឌ្ឍន៍ ជនបទ (ក.អ.ជ.) ក្រសួង អប់រំ យុវជន និងកីឡា | ត្រឹមឆ្នាំ ២០៣០ ធានាថា ក្មេងស្រី និងក្មេងប្រុសទាំងអស់បញ្ចប់ការសិក្សាថ្នាក់បឋម និងមធ្យមសិក្សាដោយឥតបង់ថ្លៃ ប្រកបដោយសមធម៌និងគុណភាពនាំទៅរកលទ្ធផលសិក្សាដែលមានភាពពាក់ព័ន្ធ និងប្រកបដោយប្រសិទ្ធភាព | ៤.ក.១ សមាមាត្រនៃសាលាមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សាដែលមានហេដ្ឋារចនាសម្ព័ន្ធ (សម្ភារ/ឧបករណ៍) ទឹកសម្រាប់ផឹកជាមូលដ្ឋាន |
| | | ៤.ក.២ សមាមាត្រនៃសាលាមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សា ដែលមានហេដ្ឋារចនាសម្ព័ន្ធអនាម័យជាមូលដ្ឋាន (basic sanitation facilities) |
| | | ៤.ក.៣ សមាមាត្រនៃសាលាមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សាដែលមានកន្លែង/ហេដ្ឋារចនាសម្ព័ន្ធសម្រាប់លាងសម្អាតដៃជាមូលដ្ឋាន |
| | | ៤.ក.៤ %នៃសាលារៀនដែលមានហេដ្ឋារចនា-សម្ព័ន្ធ និងសម្ភារដែលត្រូវបានកែតម្រូវសម្រាប់សិស្សពិការ |
| ក្រសួង កិច្ចការនារី (MoWA) | ៥.៥. ធានាការចូលរួមដោយពេញលេញប្រសិទ្ធភាព និងឱកាសស្មើភាពរបស់ស្ត្រីនៅក្នុងការដឹកនាំនៅគ្រប់កម្រិតថ្នាក់នៃជីវិតសេដ្ឋកិច្ច នយោបាយ និងសាធារណៈ | ៥.៥.៣ ចំនួនវិធានការ និងកម្មវិធីជាក់លាក់ដើម្បីលើកកម្ពស់ស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រងគ្រប់កម្រិតថ្នាក់ |
| គោលដៅទី ១៣៖ ចាត់វិធានការបន្ទាន់ ដើម្បីប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ | | |
| ក្រសួង បរិស្ថាន (MoE) | ១៣.១ ពង្រឹងភាពធន់ និងសមត្ថភាពបន្សាំចំពោះមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះធម្មជាតិដែលទាក់ទងនឹងអាកាសធាតុ | ១៣.១.១ %នៃសហគមន៍ក្នុងឃុំដែលងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុជាមួយនឹងជម្រើសបច្ចេកវិទ្យាសមស្របដែលមានភាពធន់នឹងអាកាសធាតុ |
| | ១៣.៣ កែលម្អការអប់រំ ការផ្សព្វផ្សាយ សមត្ថភាពមនុស្ស និងស្ថាប័នដើម្បីកាត់បន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុការកាត់បន្ថយផលប៉ះពាល់ នឹងការជូនដំណឹងជាមុន | ១៣.៣.៤% នៃគ្រួសារ/ខ្នងផ្ទះ និងសមាជិកសហគមន៍មូលដ្ឋាន ដែលចូលរួមសិក្ខាសាលា និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ |

NAP II ឆ្នាំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដោយផ្អែកលើឯកសារគោលនយោបាយទាំងឡាយដូចខាងក្រោម៖

1. ផែនការយុទ្ធសាស្ត្ររបស់កម្ពុជា ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៤-២០២៣
2. ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ ២០១៦-២០២០ របស់ក្រសួងសុខាភិបាល
3. ផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភ ឆ្នាំ ២០១៤-២០២០ របស់កម្មវិធីអាហារូបត្ថម្ភជាតិ/កម្ពុជា
4. 4NAP សម្រាប់កត្តាប្រឈមនៃភាពគ្មានគ្រោះអត់ឃ្លាននៅក្នុងប្រទេសកម្ពុជា ឆ្នាំ ២០១៦-២០២៥
5. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១១-២០២០
6. ក្របខណ្ឌគោលនយោបាយជាតិសម្រាប់សន្តិសុខសង្គម ក្នុងឆ្នាំ ២០១៥

7. ក្របខណ្ឌគោលនយោបាយជាតិ ស្តីពី ការគាំពារសង្គម ឆ្នាំ ២០១៦-២០២៥
8. គោលនយោបាយជាតិ ស្តីពីប្រជាពលរដ្ឋ ឆ្នាំ ២០១៦-២០៣០ ដែលផ្តល់នូវការវិភាគនិន្នាការប្រជាសាស្ត្រសំខាន់ៗ រួមទាំង យុវជន យេនឌ័រ ចំណាកស្រុក នគរូបនីយកម្ម និងមនុស្សចាស់។

## ៣.២ គោលការណ៍ណែនាំជាតិសម្រាប់អនុវត្ត NAP II

គោលការណ៍ណែនាំជាតិមួយចំនួនត្រូវបានរៀបចំឡើងដើម្បីជួយនៅក្នុងការអនុវត្ត NAP II ។ គោលការណ៍ ណែនាំជាតិទាំងនេះ ផ្តល់ព័ត៌មានបន្ថែមអំពីប្រធានបទសំខាន់ៗរួមមានដូចខាងក្រោម៖

| គោលការណ៍ណែនាំជាតិ | ខ្លឹមសាររួម |
|---|---|
| ការផ្គត់ផ្គង់ទឹក | |
| គោលការណ៍ណែនាំជាតិស្តីពីគុណភាពទឹក ផឹកជនបទ | ពិពណ៌នាអំពីស្តង់ដារគុណភាពទឹកជាអនុសាសន៍ |
| គោលការណ៍ណែនាំជាតិ ស្តីពីផែនការសុវត្ថិភាពទឹក | មគ្គុទ្ទេសក៏ជាជំហានៗសម្រាប់ដំណើរការរៀបចំផែនការសុវត្ថិភាពទឹក |
| គោលការណ៍ណែនាំជាតិ ស្តីពីការបន្សុទ្ធ និងការស្តុកទឹកទុកឱ្យមានសុវត្ថិភាពតាមគ្រួសារ | ពិពណ៌នាអំពីវិធីសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ប្រព្រឹត្តិកម្មទឹកនៅតាមគ្រួសារ |
| គោលការណ៍ណែនាំជាតិ ស្តីពីការឧបត្ថម្ភធនលើ វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទសម្រាប់គ្រួសារក្រីក្រ | ការឧបត្ថម្ភធនសម្រាប់ការផ្គត់ផ្គង់ទឹក គឺជាមធ្យោបាយមួយដើម្បីកាត់បន្ថយ ឬលុបចំបាត់ឧបសគ្គផ្នែកហិរញ្ញវត្ថុឆ្ពោះទៅការប្រើប្រាស់ទឹកស្អាតដែលមានការកែលម្អនៅក្នុងចំណោមសហគមន៍ និងគ្រួសារនៅតាមជនបទដែលជួបការលំបាក។ |
| គោលការណ៍ណែនាំជាតិ ស្តីពីប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ | ពិពណ៌នាអំពីលក្ខខណ្ឌក្នុងការផ្តល់សេវា និងជម្រើសបច្ចេកទេសដែលមានភាពបន្សាំនឹងបម្រែបម្រួលអាកាសធាតុ |
| ការរស់នៅស្អាត និងអនាម័យខ្លួនប្រាណ | |
| សហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) | មគ្គុទ្ទេសក៏ជាជំហានៗសម្រាប់ដំណើរការ CLTS រួមទាំងការពិនិត្យផ្ទៀងផ្ទាត់ |
| គោលការណ៍ណែនាំជាតិ ស្តីពីឧបត្ថម្ភសម្ភារឧបករណ៍សម្រាប់អនាម័យ | ពិពណ៌នាអំពីរបៀបដែលគួរប្រើឧបត្ថម្ភសម្ភារ ឧបករណ៍សម្រាប់អនាម័យតាមគ្រួសារ |
| គោលការណ៍ណែនាំជាតិ ស្តីពី WASH សម្រាប់ជនពិការ និងមនុស្សចាស់ | ពិពណ៌នាអំពីវិធីសាស្ត្របរិយាប័ន្នសម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យខ្លួនប្រាណ |
| អនាម័យនៅក្នុងបរិស្ថានប្រឈមសម្រាប់គ្រួសារនៅជនបទ | និយមន័យនៃតំបន់ដែលមានការលំបាក និងការណែនាំអំពីដំណោះស្រាយអនាម័យ/សុខភាព |

បន្ថែមពីលើគោលការណ៍ណែនាំទាំងនេះ មានសៀវភៅណែនាំមួយចំនួនទៀតរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បី គាំទ្រដល់ការពង្រីកការអនុវត្ត NAP II រួមបញ្ចូលទាំងសៀវភៅណែនាំ ស្តីពីការសាងសង់បង្គន់តាមគ្រួសារ និងគោលការណ៍ណែនាំស្តីពីការលាងសម្អាតដៃនឹងសាប៊ូ។

## ៣.៣ លទ្ធផលរំពឹងទុក

ក្នុងគោលដៅរួមចំណែកដល់ការសម្រេចបានទស្សនវិស័យរបស់វិស័យនៃការគ្របដណ្តប់ជាសកលនូវការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ NAP II 2019-2023 ត្រូវបានរៀបចំឡើងដើម្បីសម្រេចបានលទ្ធផលដូចខាងក្រោម៖

**តារាងទី ៣: NAP II - លទ្ធផលរំពឹងទុក សូចនាករ និងចំណុចដៅ**

| លទ្ធផលរំពឹងទុក៖ ត្រឹមឆ្នាំ ២០២៣ ប្រជាពលរដ្ឋនៅជនបទទទួលបានកាន់តែច្រើននូវទឹកសម្រាប់ផឹក ការរស់នៅស្អាត និងអនាម័យខ្លួនប្រាណប្រកបដោយសមធម៌ សុវត្ថិភាព និងតម្លៃសមរម្យ | | | | |
|---|---|---|---|---|
| សូច នាករលទ្ធផល | ទិន្នន័យគោល (%) | ចំណុចដៅ ឆ្នាំ ២០២៣ (%) | គម្លាតដែលត្រូវបំពេញ (ប្រជាពលរដ្ឋ)[២៦] | គម្លាត ដែលត្រូវបំពេញ (គ្រួសារ/ខ្នងផ្ទះ) |
| គ្រួសារនៅជនបទប្រើសេវាផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន | ៥៨,៧[២៧] | ៩០ | ៣.៥២៩.៧៧១ | ៧៩៧.៨៣៩ |
| គ្រួសារនៅជនបទប្រើសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានការគ្រប់គ្រងដោយសុវត្ថិភាព | ១៦[២៨] | ៣៣ | ២.២៣០.៩០០ | ៥០៤.៥០០ |
| គ្រួសារនៅជនបទប្រើសេវាអនាម័យជាមូលដ្ឋាន | ៧១,២[២៩] | ៩០ | ២.២៦៤.៨៣៦ | ៥១១.៩២៨ |
| គ្រួសារនៅជនបទប្រើសេវាអនាម័យដែលមានការគ្រប់គ្រងដោយសុវត្ថិភាព | មិនមាន | ៣៥ | ៤.៥៩៣.០៩០ | ១.០៨៤.០០០ |
| គ្រួសារនៅជនបទមានកន្លែងលាងសម្អាតដៃនឹងសាប៊ូ | ៧៧,១[៣០] | ៩០ | ១.៦៩២.៨៦០ | ៣៨៣.០០០ |

[២៦] ចំនួនគម្លាតប្រជាពលរដ្ឋត្រូវការទទួលបានទឹកស្អាតនិងអនាម័យជនបទដែលបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណថវិកា NAP II ត្រូវបានប៉ាន់ប្រមាណដោយយោងទៅលើ ការអង្កេតសង្គមកិច្ចសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៧ ដោយរួមបញ្ចូលទឹកផឹកដបនៅតំបន់ជនបទ (បច្ចុប្បន្នមានចំនួន ២%) ជាទឹកដែលបានកែលម្អ (ឱ្យស៊ីជាមួយនិយមន័យរបស់ JMP)។ ចំនួនគម្លាតប្រជាពលរដ្ឋ ដើម្បីសម្រេចបាន ៩០% ប្រជាពលរដ្ឋជនបទ ទទួលបានសេវាការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ មូលដ្ឋានត្រឹមឆ្នាំ ២០២៣ ត្រូវបានប៉ាន់ស្មានដោយផ្អែកលើចំនួនប្រជាពលរដ្ឋជនបទក្នុង CSES ឆ្នាំ ២០១៧ (12.047.000 នាក់) ដោយមិនបានរាប់បញ្ចូលព្យាករណ៍កំណើនប្រជាពលរដ្ឋរហូតដល់ឆ្នាំ ២០២៣ ឡើយ។

[២៧] ការអង្កេតសង្គមកិច្ចសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៧ ។

[២៨] washdata.org.

[២៩] ការអង្កេតសង្គមកិច្ចសេដ្ឋកិច្ចកម្ពុជា (CSES) ឆ្នាំ ២០១៧ ។

[៣០] ក្រសួងអភិវឌ្ឍន៍ជនបទ (២០១៦) ការអង្កេតចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត (KAP) ។

លទ្ធផលរំពឹងទុកខាងលើ នឹងត្រូវសម្រេចឱ្យបានតាមរយៈធាតុចេញដែលពង្រឹងគ្នាទៅវិញទៅមកចំនួន ៤ និង កម្រងសកម្មភាពមួយចំនួន ដូចដែលបានបង្ហាញខាងក្រោម៖

### តារាងទី ៤: កម្រងសកម្មភាព

| ធាតុចេញ/លទ្ធផល | កម្រងសកម្មភាព |
|---|---|
| I. MRD, PDRDs, PWGs និងអាជ្ញាធរមូលដ្ឋានបានពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងសម្របសម្រួលដើម្បីស្វែងរកការគាំទ្រក្នុងការវិភាជថវិកាជាតិបន្ថែមទៀត និងត្រួតពិនិត្យតាមដានកម្មវិធី RWSSH រួមទាំងក្នុងស្ថាប័ននានា (សាលារៀននិងមណ្ឌលសុខភាព) ក្នុងពេលមានគ្រោះអាសន្ន | A. កែលម្អដំណើរការរបស់រចនាសម្ព័ន្ធសម្របសម្រួល RWSSH នៅថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេស ផ្តោតលើទំនាក់ទំនងអន្តរវិស័យ<br>B. រៀបចំនិងអនុវត្តអភិវឌ្ឍន៍សមត្ថភាពជាតិ (CDP) ស្តីពី RWSSH រួមទាំងការពិនិត្យឡើងវិញលើមុខងារនិងការទទួលខុសត្រូវ<br>C. ពង្រីកនិងអនុវត្ត RWSSH-MIS ថ្នាក់ជាតិ<br>D. រៀបចំ ពិនិត្យឡើងវិញ ផ្សព្វផ្សាយ និងត្រួតពិនិត្យ តាមដានការអនុវត្តក្របខណ្ឌគ្រប់គ្រង និងគោលការណ៍ណែនាំដែលទាក់ទងនឹង RWSSH<br>E. ស្នើសុំបង្កើនការវិភាជថវិកាជាតិសម្រាប់ RWSSH<br>F. ការគាំទ្រផ្នែកបច្ចេកទេស និងការស្នើសុំបង្កើនការវិភាជថវិកានៅក្រោមជាតិសម្រាប់ RWSSH<br>G. ពង្រីក និងពង្រឹងស្រុកដែលទទួលបានការផ្ទេរមុខងារសម្រាប់ RWSSH |
| II. ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម និងតំបន់ដែលប៉ះពាល់ដោយសារធាតុអាសេនិកទទួលបានកាន់តែច្រើន សមធម៌និងនិរន្តរភាពនូវសេវាផ្គត់ផ្គង់ទឹកសម្រាប់ផឹកដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | A. សាងសងថ្មី និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលមានភាពធន់ និងមិនប្រឈមមុខសញ្ញាគ្រោះថ្នាក់<br>B. រៀបចំ និងអនុវត្ត WSPs នៅជនបទដែលមានភាពធន់ទៅនឹងអាកាសធាតុ<br>C. កែលម្អហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមសាលារៀនជនបទ និងមណ្ឌលសុខភាពផ្អែកតាមស្តង់ដារជាតិដោយសហការជាមួយក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា<br>D. បង្កើតបញ្ជីសារពើភ័ណ្ឌផ្គត់ផ្គង់ទឹកស្អាតជនបទ<br>E. ការត្រួតពិនិត្យ តាមដានគុណភាពទឹក |

| ធាតុចេញ/លទ្ធផល | កម្រងសកម្មភាព |
| --- | --- |
| III. ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម ទទួលបានកាន់តែច្រើន និងប្រកបដោយសមធម៌ និងនិរន្តរភាពនូវសេវាអនាម័យដែលត្រូវបានគ្រប់គ្រងដោយ សុវត្ថិភាព | A. រៀបចំ និងអនុវត្តផែនការខេត្តសម្រាប់ ODF ដែលដឹកនាំដោយ រាជរដ្ឋាភិបាល រួមបញ្ចូលទាំងការប្រើប្រាស់ប្រាក់ឧបត្ថម្ភធនឆ្លាតវៃ សម្រាប់គ្រួសារក្រីក្រ<br>B. លើកកម្ពស់ការចូលរួមដែលមានរចនាសម្ព័ន្ធរវាងទីផ្សារនិងវិធីសាស្ត្រអនាម័យតាមសហគមន៍ ដោយផ្តោតជាពិសេសទៅលើក្រុម និងសហគមន៍ដែលបាត់បង់ឱកាសនៅក្នុងបរិស្ថានប្រឈម។<br>C. កែលម្អហេដ្ឋារចនាសម្ព័ន្ធអនាម័យនៅក្នុងសាលារៀននៅជនបទ និងមណ្ឌលសុខភាពដើម្បីឆ្លើយតបតាមបទដ្ឋានជាតិ និងសមស្របក្នុងការឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុដោយសហការជាមួយក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។ |
| IV. ប្រជាពលរដ្ឋនៅជនបទកែលម្អឥរិយាបថអនាម័យដែលទាក់ទងនឹងទឹកសម្រាប់ផឹកដែលមានសុវត្ថិភាព ការរស់នៅស្អាត និងការលាងសម្អាតដៃនឹងសាប៊ូ | A. រៀបចំអនុវត្ត និងពិនិត្យឡើងវិញយុទ្ធនាការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទង ទាក់ទងនឹង RWSSH(BCC) ដើម្បីកែលម្អឥរិយាបថអនាម័យនៅក្នុងសហគមន៍។<br>B. រៀបចំ អនុវត្តនិងពិនិត្យឡើងវិញផែនការ BCC សម្រាប់ RWSSH ដើម្បីកែលម្អឥរិយាបថអនាម័យរបស់សិស្សសាលា។<br>C. លើកកម្ពស់ការសិក្សា/ការអភិវឌ្ឍចំណេះដឹង ស្តីពីការផ្លាស់ប្តូរឥរិយាបថអនាម័យ |

លទ្ធផលរំពឹងទុកសំខាន់ៗក្រោមធាតុចេញនីមួយៗក្នុងចំណោមធាតុចេញទាំងបួន ត្រូវរៀបរាប់ក្នុងតារាងទី ៥ ។

**តារាងទី ៥: លទ្ធផលរំពឹងទុក/ធាតុចេញ**

| ធាតុចេញ | លទ្ធផលរំពឹងទុក |
|---|---|
| MRD, PDRDs, PWGs និងអាជ្ញាធរមូលដ្ឋាន បានពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងសម្របសម្រួល ដើម្បីស្នើសុំការវិភាជថវិកាជាតិបន្ថែមទៀត និងត្រួតពិនិត្យ តាមដានកម្មវិធី RWSSH រួមទាំងក្នុងស្ថាប័ន និងក្នុងពេលមានគ្រោះអាសន្ន។ | • បុគ្គលិក MRD/PDRD ចំនួន ១០០ នាក់ បានទទួលការបណ្តុះបណ្តាល និងប្រើប្រាស់វេទិកាសិក្សាដែលបានបង្កើតឡើង ជាទៀងទាត់។<br>• PWGs នៃខេត្តទាំង ២៥ និងជនបង្គោល RWSSH មកពីយ៉ាងតិច ៥០ ស្រុកបានទទួលការបណ្តុះបណ្តាល និងប្រើប្រាស់វេទិកាសិក្សាដែលបានបង្កើតឡើង ជាទៀងទាត់។<br>• PWGs នៃខេត្តទាំង ២៥ ចូលរួមប្រជុំជាទៀងទាត់ ដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃការអនុវត្ត PAPsនិងមានសមត្ថភាពរាយការណ៍អំពីស្ថានភាពនៃសូចនាករ PAPយ៉ាងតិច ៥០% តាមរយៈ MIS<br>• ផែនការត្រៀមទទប់ទល់និងឆ្លើយតបគ្រោះអាសន្ននៃ RWSSH ត្រូវបានរៀបចំឡើងនិងអនុម័តនៅក្នុង ១៦ ខេត្ត<br>• យ៉ាងតិច ១.៥០០ ឃុំនិង ៧៨ ស្រុក វិភាជថវិកាសម្រាប់ RWSSH នៅក្នុងផែនការវិនិយោគឃុំ និងផែនការវិនិយោគស្រុក<br>• ថវិកាជាតិសម្រាប់ RWSSH កើនឡើងយ៉ាងតិច ១០% ជារៀងរាល់ឆ្នាំ<br>• កិច្ចប្រជុំសម្របសម្រួលយ៉ាងតិចចំនួន ២ ដងក្នុងមួយឆ្នាំ ស្តីពី WASHនិងអាហារូបត្ថម្ភ, WASH នៅក្នុងមណ្ឌលសុខភាព និង WASH នៅក្នុងសាលារៀន<br>• បទប្បញ្ញត្តិយ៉ាងតិច ១ ស្តីពីការចូលរួមរបស់វិស័យឯកជននៅក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកដែលគ្រប់គ្រងដោយសហគមន៍ ត្រូវបានអនុម័តនិងផ្សព្វផ្សាយ<br>• ស្រុកយ៉ាងតិច ២០ អនុវត្តមុខងារដែលបានផ្ទេរសម្រាប់ការផ្គត់ផ្គង់ទឹកនៅជនបទ និង ៥០ ស្រុក អនុវត្តមុខងារសម្រាប់អនាម័យជនបទ |

| ធាតុចេញ | លទ្ធផលរំពឹងទុក |
|---|---|
| ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម និងតំបន់ដែលប៉ះពាល់ដោយសារធាតុអាសេនិក ទទួលបានកាន់តែច្រើនប្រកបដោយសមធម៌និងនិរន្តរភាពនូវសេវាទឹកសម្រាប់ផឹកដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | • ៧០% នៃគ្រួសារក្រីក្រ ទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន<br>• ៧០% នៃគ្រួសារដែលរស់នៅក្នុងបរិស្ថានប្រឈមទទួលបានសេវាទឹកស្អាត និងអនាម័យជាមូលដ្ឋាន<br>• ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមទុយោដែលគ្រប់គ្រងដោយសហគមន៍ចំនួន ៧៧០ និងប្រព័ន្ធទឹកសម្រាប់ផឹកដោយប្រើធុងបដែលគ្រប់គ្រងដោយសហគមន៍ចំនួន ៣០០ (២០ លីត្រ)ត្រូវបានបង្កើតឡើងនិងមានដំណើរការ<br>• អណ្តូងទឹកដែលមានភាពធន់ទៅនឹងអាកាសធាតុចំនួន ១៩,៥០០ អណ្តូងទឹកដែលមានការការពារចំនួន ៨,០០០ និងប្រព័ន្ធប្រមូលទឹកភ្លៀងគ្រួសារចំនួន៨,០០០ ដែលអនុលោមទៅតាមសៀវភៅណែនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការសាងសង់និងគំនូរប្លង់បច្ចេកទេសផ្គត់ផ្គង់ទឹកជនបទ<br>• ឃុំចំនួន ៥០០ ឃុំ អនុវត្ត WSPs ដែលដាក់បញ្ចូលគោលការណ៍បន្សុំាការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ<br>• ខេត្តទាំង ២៥ រាយការណ៍លទ្ធផលប្រចាំឆ្នាំអំពីការត្រួតពិនិត្យតាមដានគុណភាពទឹក<br>• ៦០%នៃសាលាមត្តេយ្យ (មត្តេយ្យរដ្ឋ) ៦៥%នៃសាលាបឋមសិក្សា ៥០%នៃសាលាអនុវិទ្យាល័យ និង៦០%នៃសាលាវិទ្យាល័យ ទឹកស្អាត<br>• ១០០% នៃមូលដ្ឋានសុខាភិបាលសាធារណៈ មានផ្គត់ផ្គង់ទឹកប្រើប្រាស់ជាមូលដ្ឋាន |

| ធាតុចេញ | លទ្ធផលរំពឹងទុក |
|---|---|
| ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម ទទួលបានកាន់តែច្រើនប្រកបដោយសមធម៌ និងនិរន្តរភាពនូវសេវាអនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | • ១២.៧០០ ភូមិ (ភូមិចំនួន ១០.៩១១ បន្ថែមទៀត) ៦០០ ODF ឃុំ (ឃុំចំនួន ៥២៨ បន្ថែមទៀត) ៣០ ODF ស្រុក (២៨ ស្រុកបន្ថែមទៀត) និង ៣ខេត្ត សម្រេចបានស្ថានភាព ODF ។<br>• ចំនួនសហគមន៍ ODF មាននិរន្តរភាពពីមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យនៃអាកាសធាតុ<br>• យ៉ាងតិច ៥.០០០ ភូមិ រក្សាស្ថានភាព ODF បានយ៉ាងតិច៣ឆ្នាំ<br>• យ៉ាងតិច ៣០ ស្រុក មានសហគ្រិនអនាម័យ ដែលផ្តល់សេវាគ្រប់គ្រងសំណល់លាមកខាងក្រៅ<br>• យ៉ាងតិច ៣៦ស្រុក មានសហគ្រិនផ្តល់សេវាអនាម័យ ដែលផ្តល់ផលិតផល សម្រាប់បរិស្ថានប្រឈម<br>• ៣៥% នៃគ្រួសារ ប្រើសេវាគ្រប់គ្រងសំណល់លាមកនៅនឹងកន្លែង<br>• ៧០% នៃគ្រួសារនៅក្នុងបរិស្ថានប្រឈម ទទួលបានសេវាជាមូលដ្ឋាន ហើយ៣០% ទទួលបានសេវា អនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព<br>• ៨០% នៃសាលាមត្តេយ្យ (មត្តេយ្យរដ្ឋ) ៩៥%នៃសាលាបឋម ៩៥%នៃសាលាអនុវិទ្យាល័យ និង១០០%នៃសាលាវិទ្យាល័យមានបង្គន់អនាម័យប្រើប្រាស់<br>• ៦០% នៃសាលាមត្តេយ្យ (មត្តេយ្យរដ្ឋ) ៦៥%នៃសាលាបឋម ៨៥%នៃសាលាអនុវិទ្យាល័យ និង៦០%នៃសាលាវិទ្យាល័យ មានសម្ភារឧបករណ៍សម្រាប់លាងសម្អាតដៃ<br>• ១០០% នៃមូលដ្ឋានសុខាភិបាលសាធារណៈ មានបង្គន់អនាម័យ |

| ធាតុចេញ | លទ្ធផលរំពឹងទុក |
|---|---|
| ប្រជាពលរដ្ឋនៅជនបទកែលម្អឥរិយាបថអនាម័យដែលទាក់ទងនឹងទឹកសម្រាប់ផឹកដែលមានសុវត្ថិភាពអនាម័យនិងការលាងសម្អាតដៃនឹងសាប៊ូ | • ៩០% នៃគ្រួសារធ្វើការចម្រោះទឹកជានិច្ចជាកាល (កើនឡើងពី ៧៧,៦%)<br>• ៩០% នៃគ្រួសារ ជានិច្ចកាលប្រើបង្គន់ដែលមានកន្លែងសម្រាប់លាងសម្អាតដៃដែលមានសាប៊ូ<br>• ៩០% នៃអ្នកថែទាំកុមារអាយុក្រោម ៥ ឆ្នាំ គ្រប់គ្រងលាមកកុមារដោយសុវត្ថិភាពនិងអនុវត្តការលាងសម្អាតដៃនឹងសាប៊ូនៅក្នុងពេលវេលាសំខាន់ៗ<br>• ៩០% នៃគ្រួសារមានកន្លែងមួយសម្រាប់លាងសម្អាតដៃនឹងសាប៊ូ (កើនឡើងពី ៧៦%)<br>• ៩០% នៃសិស្សសាលា អនុវត្តការលាងសម្អាតដៃនឹងសាប៊ូក្នុងពេលវេលាសំខាន់ៗ<br>• ២០០ ឃុំ លើកកម្ពស់ការគ្រប់គ្រងអនាម័យពេលមានរដូវ<br>• យុទ្ធនាការ BCC ជាតិ ត្រូវបានរៀបចំឡើង អនុវត្ត តាមដាននិងត្រួតពិនិត្យ |

ចំណុចដៅប្រចាំឆ្នាំដែលបានកំណត់ ត្រូវបានបង្ហាញនៅក្នុងម៉ាទ្រីស តាមដាននិងត្រួតពិនិត្យការអនុវត្តនៅក្នុងឧបសម្ព័ន្ធទី I ។

## ៣.៤ ការដោះស្រាយបញ្ហាអន្តរវិស័យ

NAP II មានបំណងដោះស្រាយបញ្ហាអន្តរវិស័យសំខាន់ៗទាំងឡាយដូចខាងក្រោម៖

- ពង្រឹងការយកចិត្តទុកដាក់លើក្រុមដែលបាត់បង់ឱកាស តាមរយៈអន្តរាគមន៍ដែលផ្តោតគោលដៅលើគ្រួសារដែលមានភាពងាយរងគ្រោះខ្ពស់។ គ្រួសារទាំងនេះនឹងរួមបញ្ចូលទាំងគ្រួសារដែលមានប័ណ្ណក្រីក្រ (គ្រួសារទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណថា ក្រីក្រ) និងអ្នកដែលកំពុងរស់នៅក្នុងបរិស្ថានប្រឈម។ ផ្អែកតាមអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១១ គ្រួសារដែលមេគ្រួសារ (ប្តី ឬប្រពន្ធ) មានពិការភាពធ្ងន់ធ្ងរ ឬជំងឺរ៉ាំរ៉ៃ ដែលមានសមាជិកសុទ្ធតែចាស់ជរា មានក្មេងកំព្រារស់នៅជាមួយពួកគេ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ដែលមានកុមារតូចៗច្រើន ឬគ្រួសារដែលគ្មានសមាជិកដែលមានសមត្ថភាពធ្វើការនោះ នឹងត្រូវដាក់បញ្ចូលក្នុងចំណាត់ថ្នាក់ក្រីក្រ។ គោលការណ៍ណែនាំជាតិ ស្តីពីការផ្តល់ឧបត្ថម្ភធនដល់គ្រួសារក្រីក្រ ដែលផ្តោតលើអនាម័យនឹងត្រូវបានប្រើប្រាស់។ គោលការណ៍ស្រដៀងគ្នានេះដែរ នឹងត្រូវបានបង្កើតឡើងសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត។ វឌ្ឍនភាពក្នុងការដោះស្រាយបញ្ហាវិសមភាពនៃសេវា នឹងត្រូវបានតាមដាននិងត្រួតពិនិត្យ តាមរយៈសូចនាករជាក់លាក់ដែលបានបង្កើតរួចហើយ។
- ដាក់បញ្ចូលអន្តរាគមន៍ជាក់លាក់និងសូចនាករដែលផ្តោតលើអាហារូបត្ថម្ភ ដើម្បីរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលអាហារូបត្ថម្ភ បន្ថែមពីលើការរួមចំណែកជារួមពីការកែលម្អ RWSSH ។

អន្តរាគមន៍ទាំងនេះ នឹងរួមបញ្ចូលទាំងការជំរុញការគ្រប់គ្រងដោយសុវត្ថិភាពនូវលាមកកុមារ និងអ្នកថែទាំកុមារអាយុក្រោម ៥ឆ្នាំ លាងដៃពួកគេជាមួយសាប៊ូ និងធានាថាមានទឹកដែលមានសុវត្ថិភាពនៅពេលរៀបចំអាហារសម្រាប់កុមារ។ ការច្របាច់បញ្ចូលគ្នានូវសេវា RWSSH ជាមួយអន្តរាគមន៍កែលម្អអាហារូបត្ថម្ភ នឹងត្រូវបានជំរុញ។

- លើកកម្ពស់ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសមត្ថភាពព្រមទាំងសកម្មភាពសំខាន់ៗ។ តម្រូវការផ្អែកលើយេនឌ័រ នឹងត្រូវបានដោះស្រាយ ឧទាហរណ៍តាមរយៈការផ្តល់បង្គន់អនាម័យដែលមានភេទដាច់ដោយឡែកពីគ្នានៅក្នុងសាលារៀននិងមណ្ឌលសុខភាព និងការលើកកម្ពស់ការគ្រប់គ្រងអនាម័យពេលមានរដូវ។ លទ្ធផលនិងមេរៀនដែលទទួលបានពីគំនិតផ្តួចផ្តើមនៃកម្មវិធីផ្សេងៗនៅក្នុងវិស័យនេះ នឹងត្រូវបានប្រើប្រាស់និងកសាងបន្ត។
- ការដាក់បញ្ចូលការបន្សុំាភាពធន់នឹងអាកាសធាតុនិងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយតាមរយៈ
    - ការយល់ដឹងអំពីហានិភ័យពាក់ព័ន្ធនឹងអាកាសធាតុនៅក្នុងវិស័យទឹកស្អាតនិងអនាម័យ
    - អនុវត្ត WSPs ដែលមានភាពធន់នឹងអាកាសធាតុ
    - ការបង្កើតជម្រើសនិងគោលការណ៍ណែនាំស្តីពីការបន្សុំា ដើម្បីពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធ RWSSH ។
    - ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ស្តីពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅជនបទដែលធន់នឹងអាកាសធាតុ
    - វិធានការការពារទឹកជំនន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត
    - ការទទួលយក ការប្រើបង្គន់ខ្ពស់និងសំណង់ហេដ្ឋារចនាសម្ព័ន្ធអនាម័យនៅជនបទ/ទីប្រជុំជននៅលើកកម្រិតទឹកផ្សេងទៀត
    - ការរៀបចំផែនការ RWSSH ដើម្បីត្រៀមបង្ការនិងឆ្លើយតបគ្រោះអាសន្នដែលបណ្តាលមកពីខ្យល់ព្យុះ ទឹកជំនន់និងគ្រោះធម្មជាតិដែលពាក់ព័ន្ធ ។

## ៣.៥ RWSSH PAPs ឆ្នាំ ២០១៩-២០២៣

លទ្ធផលរំពឹងទុក និងធាតុចេញរបស់ NAP II គឺជាមូលដ្ឋានសម្រាប់ការបង្កើត RWSSH 2019-2023 PAPs នៅក្នុងខេត្តនីមួយៗក្នុងចំណោមខេត្តទាំង២៥ ។ ចំណុចដៅដែលបានកំណត់របស់ខេត្តនីមួយៗសម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជាមូលដ្ឋានមានបង្ហាញនៅក្នុងរូបភាពទី៨ ។ PAPs ទាំងនេះកំពុងត្រូវបានពិនិត្យឡើងវិញដើម្បីបញ្ចប់ជាចុងក្រោយនៅចុងខែមករា ឆ្នាំ២០១៩ ។

### រូបភាពទី ៤: ចំណុចដៅនៃ PAP II-សេវាផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន




*Source: (PAPs RWSSH 2019-2023)*

### រូបភាពទី ៥: ចំណុចដៅនៃ PAP II-សេវាអនាម័យ/សុខភាពជាមូលដ្ឋាន




*Source: (PAPs RWSSH 2019-2023)*

រូបភាពទី ៦: ចំណុចដៅនៃ PAP II-សេវាអនាម័យខ្លួនប្រាណជាមូលដ្ឋាន




*Source: (PAPs RWSSH 2019-2023)*

ចំណុចដៅបានកំណត់សម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទដែលមានការគ្រប់គ្រងដោយសុវត្ថិភាពមិនទាន់ត្រូវបានផ្ទៀងផ្ទាត់ទេ ដូច្នេះមិនត្រូវបានបង្ហាញឡើយ។

## ៣.៦ គម្រោងពេលសម្រាប់អនុវត្តន៍

ការអនុវត្ត NAP II គ្របដណ្តប់លើរយៈពេលពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ រយៈពេលនេះស្របតាមអាណត្តិរបស់រាជរដ្ឋាភិបាល បច្ចុប្បន្ននិងក្របខណ្ឌផែនការជាតិ រួមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទផងដែរ។

នៅថ្នាក់ជាតិ ការអនុវត្ត NAP II នៅឆ្នាំទី១ នឹងផ្តោតទៅលើ៖

- ការផ្សព្វផ្សាយ NAP II និង PAPs II បន្ទាប់មក មានការរៀបចំគោលការណ៍ណែនាំបច្ចេកទេសសម្រាប់អនុវត្តន៍
- ការផ្ទៀងផ្ទាត់ទិន្នន័យគោលសម្រាប់សូចនាករសំខាន់ៗមួយចំនួន
- ការផ្ទៀងផ្ទាត់ប្រភពថវិកាសម្រាប់កម្រងសកម្មភាព
- ការបង្កើត CDP និងការចាប់ផ្តើមការអនុវត្ត

- ការបង្កើតនិងពង្រីក MIS ដើម្បីគ្រប់គ្រងវឌ្ឍនភាពនៃការតាមដានត្រួតពិនិត្យតាមដានសំខាន់ៗ
- ការពិនិត្យឡើងវិញ និងអភិវឌ្ឍគោលការណ៍ណែនាំបច្ចេកទេស
- ការបង្កើតគោលការណ៍ណែនាំជាតិស្តីពី BCC ។

PAPs II រួមបញ្ចូលផែនការលម្អិតថែមទៀតសម្រាប់អនុវត្តន៍ក្នុងឆ្នាំទី១ ដោយមានបញ្ជាក់ពីតម្រូវការថវិកាប៉ាន់ស្មាន។ គេរំពឹងថា ផែនការប្រចាំឆ្នាំជាបន្តបន្ទាប់ នឹងត្រូវបានរៀបចំឡើងផងដែរ។

## ៣.៧ ការសន្មតសំខាន់ៗ

ការសន្មតសំខាន់ៗទាំងឡាយខាងក្រោមនេះ នឹងត្រូវពិនិត្យឡើងវិញជាទៀងទាត់នៅក្នុងរយៈពេលអនុវត្តន៍។

- ដៃគូអភិវឌ្ឍន៍សំខាន់ៗ នឹងបន្តទទួលស្គាល់ការកែលម្អ RWSSH ជាកម្មវិធីអភិវឌ្ឍន៍ជាអាទិភាពមួយសម្រាប់កម្ពុជានិងការរួមចំណែករបស់ពួកគេចំពោះការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយចំនួនរបស់កម្ពុជា ជាពិសេសគោលដៅទី១ (គ្មានភាពក្រីក្រ); ២ (គ្មានភាពអត់ឃ្លាន); ៣ (សុខភាព និងសុខុមាលភាពល្អសម្រាប់មនុស្សគ្រប់រូប); ៤ (ការអប់រំប្រកបដោយគុណភាព); និង៥ (សមភាពយេនឌ័រ)។
- ដៃគូថ្មីរបស់វិស័យនេះ នឹងទទួលស្គាល់សារសំខាន់នៃការដាក់តម្រូវការគាំទ្ររបស់ពួកគេឱ្យស្របតាម RWSSH NAP II
- វិមជ្ឈការ នឹងត្រូវបានអនុវត្តតាមការគ្រោងទុក
- តួអង្គវិស័យឯកជន នឹងត្រូវបានលើកទឹកចិត្តឱ្យចូលរួម ហើយរាជរដ្ឋាភិបាល នឹងបន្តធ្វើការកែលម្អបរិយាកាសអំណោយផលសម្រាប់ការចូលរួមរបស់វិស័យឯកជន
- នឹងមិនមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុនិងគ្រោះអាសន្ននោះឡើយ។

# ៤. ការរៀបចំស្ថាប័នសម្រាប់ការអនុវត្ត

## ៤.១ ការរៀបចំស្ថាប័ន

ក្រសួងអភិវឌ្ឍន៍ជនបទគឺជាស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត NAP និងទទួលខុសត្រូវចំពោះការសម្រេចឱ្យបានលទ្ធផលរំពឹងទុក។ នាយកដ្ឋាន ផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ និងនាយកដ្ឋានថែទាំ-សុខភាពជនបទ គឺជានាយកដ្ឋានបច្ចេកទេសដែលទទួលខុសត្រូវក្នុងការសម្របសម្រួល និងដឹកនាំការអនុវត្ត NAP នៅថ្នាក់ជាតិ។

ក្រុមការងារ TWG-RWSSH មានតួនាទីក្នុងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវការឆ្លើយតបនឹងរាជរដ្ឋាភិបាល លើកម្មវិធី RWSSH នៅជនបទនឹងផ្តល់ជាវេទិកាមួយសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីសម្របសម្រួល និងតាមដានមើលវឌ្ឍនភាពលើលទ្ធផលរំពឹងទុក ដោយមានការគាំទ្រពីស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។

នៅថ្នាក់ខេត្ត មន្ទីរអភិវឌ្ឍន៍ជនបទ នឹងទទួលខុសត្រូវក្នុងការអនុវត្ត PAPs ហើយនឹងត្រូវទទួលខុសត្រូវចំពោះការសម្រេចឱ្យបានលទ្ធផលរំពឹងទុក។ PWGs-RWSSH នឹងត្រួតពិនិត្យមើលការអនុវត្ត PAPs រួមទាំងការកំណត់គោលដៅវិនិយោគ RWSSH និងផ្តល់ការគាំទ្រដល់រដ្ឋបាលស្រុក ។

ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកនៃក្រសួងអភិវឌ្ឍន៍ជនបទនឹងដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រដល់រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំ ដោយធ្វើការត្រួតពិនិត្យ តាមដាន ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការរៀបចំផែនការវិនិយោគ។ ស្រុកកាន់តែច្រើនឡើង ជាពិសេសស្រុកដែលបានអនុវត្តមុខងារ RWSSH ដែលបានផ្ទេរជូន ក្រោមគំនិតផ្តួចផ្តើមវិមជ្ឈការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានបង្កើតក្រុមការងារ RWSSH ថ្នាក់ស្រុកផងដែរ ។

ដៃគូអភិវឌ្ឍន៍ និងដៃគូអង្គការសង្គមស៊ីវិលនឹងបន្តដើរតួនាទីយ៉ាងសំខាន់នៅក្នុងការគាំទ្រការអនុវត្ត និងការត្រួតពិនិត្យ តាមដាន NAP II និង PAPs II ។ តួអង្គវិស័យឯកជនត្រូវបានគេរំពឹងថា នឹងដើរតួជាដៃគូរបស់វិស័យនេះ ហើយចូលរួមក្នុងការផ្តល់សេវា RWSSH នៅក្នុងក្របខណ្ឌនៃកម្មវិធី NAP II និង PAPs II ។ តួនាទី និងការទទួលខុសត្រូវរបស់តួអង្គផ្សេងៗ នៅកម្រិតថ្នាក់ផ្សេងៗគ្នា មានបង្ហាញនៅក្នុងតារាងទី ៦ ។

### តារាងទី ៦: ក្របខណ្ឌអនុវត្តន៍របស់ស្ថាប័ន

| កម្រិតថ្នាក់ | ស្ថាប័ន/អង្គការ | តួនាទីនិងការទទួលខុសត្រូវ |
|---|---|---|
| ជាតិ | ក្រសួងអភិវឌ្ឍន៍ជនបទ | • ដឹកនាំការអនុវត្ត NAP II<br>• សម្របសម្រួលដៃគូអភិវឌ្ឍន៍ និងស្ថាប័នអនុវត្តនៅថ្នាក់ជាតិ<br>• ពិនិត្យឡើងវិញលើ NAP II ប្រចាំឆ្នាំ<br>• កៀរគរនិងគ្រប់គ្រងធនធានសម្រាប់ RWSSH<br>• គាំទ្រដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តដើម្បីរៀបចំបង្កើត PAPs II<br>• គាំទ្រដល់ការកសាងសមត្ថភាព PDRD និង DoRD |
| | TWG-RWSSH | • គាំទ្រដល់ការត្រួតពិនិត្យមើលការអនុវត្ត NAP<br>• រៀបចំប្រជុំប្រចាំត្រីមាសដើម្បីពិនិត្យឡើងវិញលើវឌ្ឍនភាព |
| | ដៃគូអភិវឌ្ឍន៍ | • ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុដល់ដំណើរការ NAP II<br>• ការផ្តល់សេវា ការកសាងសមត្ថភាពនិងសកម្មភាពផ្សេងទៀត |
| | វិស័យឯកជន | • ចូលរួមក្នុងការផ្តល់សេវា ការកសាងសមត្ថភាពនិងសកម្មភាពផ្សេងទៀត |
| ខេត្ត | PDRD | • ដឹកនាំអនុវត្តន៍ PAP<br>• សម្របសម្រួលស្ថាប័នអនុវត្តនៅថ្នាក់ខេត្ត<br>• សម្របសម្រួលការត្រួតពិនិត្យ តាមដាន<br>• សម្របសម្រួលការត្រួតពិនិត្យ តាមដាន និងរាយការណ៍ទៅថ្នាក់ខេត្ត<br>• ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព PAPs ប្រចាំឆ្នាំ<br>• កៀរគរនិងគ្រប់គ្រងធនធានសម្រាប់ RWSSH<br>• គាំទ្រខេត្ត ស្រុក ឃុំ ក្នុងការរៀបចំផែនការ<br>• គាំទ្រ DoRD, ជនបង្គោល RWSSH ថ្នាក់ស្រុកនិងឃុំ |
| | PWG-RWSSH | • គាំទ្រដល់ការត្រួតពិនិត្យមើលការអនុវត្ត PAP<br>• រៀបចំប្រជុំប្រចាំត្រីមាសដើម្បីពិនិត្យឡើងវិញលើវឌ្ឍនភាព |
| | ដៃគូអនុវត្តន៍ | • ផ្តល់ការគាំទ្រដល់ការអនុវត្តផ្ទាល់ រួមទាំងការអភិវឌ្ឍសមត្ថភាព<br>• គាំទ្រដល់ការត្រួតពិនិត្យ តាមដាន និងការរាយការណ៍អំពីវឌ្ឍនភាព |

| កម្រិតថ្នាក់ | ស្ថាប័ន/អង្គការ | តួនាទីនិងការទទួលខុសត្រូវ |
|---|---|---|
| ស្រុក | រដ្ឋបាលស្រុក[៣១] | • រៀបចំផែនការអភិវឌ្ឍន៍ស្រុក (ផ្តោតគោលដៅវិនិយោគលើ RWSSH)<br>• គ្រប់គ្រងនិងតាមដានមើលការវិនិយោគ RWSSH ថ្នាក់ស្រុក |
| | ជនបង្គោល RWSSH ថ្នាក់ស្រុក | • កំណត់និងចាត់អាទិភាពតម្រូវការវិនិយោគលើ RWSSH<br>• ស្វែងរកការគាំទ្រសម្រាប់ការវិនិយោគលើ RWSSH ជាមួយរដ្ឋបាលស្រុក<br>• គាំទ្រដល់ការកសាងសមត្ថភាពនិងការអនុវត្ត RWSSH នៅថ្នាក់ឃុំ |
| | DORD | • ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលស្រុកនិងក្រុមប្រឹក្សាឃុំ<br>• គាំទ្រដល់ជនបង្គោល RWSSH ថ្នាក់ស្រុក |
| | ដៃគូអនុវត្តន៍ | • រួមចំណែកដល់ការអនុវត្ត PAPs<br>• រៀបចំផែនការសកម្មភាពជាមួយជនបង្គោល DoRD និងអាជ្ញាធរមូលដ្ឋាន |
| | ក្រុមការងារថ្នាក់ស្រុក -RWSSH | • គ្រប់គ្រង ត្រួតពិនិត្យលើការអនុវត្ត PAP<br>• រាយការណ៍ជូន PWG-RWSSH អំពីវឌ្ឍនភាព |
| ឃុំ | ក្រុមប្រឹក្សាឃុំ | • រៀបចំផែនការអភិវឌ្ឍន៍ឃុំ (ផ្តោតគោលដៅលើការវិនិយោគ)<br>• គ្រប់គ្រងនិងតាមដានការវិនិយោគឃុំ<br>• គាំទ្រដល់ការអនុវត្តនៅថ្នាក់សហគមន៍ |
| | គណៈកម្មាធិការឃុំពិគ្រោះយោបល់ស្ត្រីពីនារីនិងកុមារ | • គាំទ្រដល់យុទ្ធនាការថ្នាក់ភូមិ<br>• ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំអំពីការវិនិយោគ RWSSH |
| | ជនបង្គោល RWSSH ថ្នាក់ឃុំ[៣១] | • ស្វែងរកការគាំទ្រសម្រាប់ការវិនិយោគ RWSSH<br>• គាំទ្រដល់យុទ្ធនាការនិងការអភិវឌ្ឍសមត្ថភាព<br>• គាំទ្រនិងកសាងសមត្ថភាពរបស់ជនបង្គោលថ្នាក់ភូមិនិងភាគីពាក់ព័ន្ធនៃ RWSSH ផ្សេងទៀត |

[៣១] បុគ្គលដែលតែងតាំងដោយរដ្ឋបាលស្រុក ដើម្បីសម្របសម្រួល និងគាំទ្រការអនុវត្ត RWSSH ។
[៣២] បុគ្គលដែលតែងតាំងដោយក្រុមប្រឹក្សាឃុំ ដើម្បីសម្របសម្រួល និងគាំទ្រការអនុវត្ត RWSSH ។

# ៤.២ ការរៀបចំសម្រាប់និរន្តរភាព

និរន្តរភាពលទ្ធផលរំពឹងទុកនឹងត្រូវបានលើកកម្ពស់តាមរយៈ៖

- ដាក់តម្រូវរចនាសម្ព័ន្ធនៃ NAP II ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ។ ផែនការជាយុទ្ធសាស្ត្រថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ នឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ការពិចារណាបែងចែកថវិកាប្រចាំឆ្នាំ។ វិស័យនេះ នឹងបន្តពង្រឹងការអនុវត្តថវិកាតាមកម្មវិធី និង "ថវិកាផ្អែកលើសមិទ្ធិកម្ម"
- ពង្រឹងភាពដឹកនាំ ភាពជាម្ចាស់ គណនេយ្យភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងសកម្មភាពទូទាំងប្រទេស តាមរយៈការដឹកនាំរបស់ PWG RWSSH
- ជំរុញការសម្រេចបានការគ្របដណ្តប់ទូទាំងឃុំ ស្រុកនិងខេត្ត រួមទាំងផែនការដើម្បីជួយដល់ខេត្តចំនួន៣ ដើម្បីសម្រេចបានជាខេត្ត ODF
- ដាក់បញ្ចូលតួអង្គវិស័យឯកជនជាអ្នកផ្តល់សេវានិងផលិតផល RWSSH
- ប្រើប្រាស់ប្រព័ន្ធដែលមានស្រាប់របស់រាជរដ្ឋាភិបាល ដើម្បីរាយការណ៍ពីវឌ្ឍនភាពឆ្ពោះទៅរកចំណុចដៅ រួមបញ្ចូលទាំង RWSSH MIS និងយន្តការរាយការណ៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

# ៥. ហិរញ្ញប្បទាន

ក្នុងការសម្រេចបានចំណុចដៅដែលបានកំណត់សម្រាប់ NAP II (២០១៩-២០២៣) ប្រជាជនប្រមាណ ៣,៥លាននាក់ដែលរស់នៅក្នុងតំបន់ជនបទ (ស្មើនឹង ៧០៥.៩៥៤ នាក់ក្នុងមួយឆ្នាំ) នឹងទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាននិងប្រហែល ២,២ លាននាក់ (ស្មើនឹង ៤៥២.៩៦៧ នាក់ក្នុងមួយឆ្នាំ) នឹងទទួលបានសេវាអនាម័យជាមូលដ្ឋាន។ នេះមានន័យថា គេត្រូវការថវិកាសាធារណៈ[៣៣] ប្រមាណ ២៨០,៦ លានដុល្លារអាមេរិក, ដែលរួមបញ្ចូលទាំងតម្រូវការវិនិយោគមូលធនសរុបៈ (៣,០លានដុល្លារអាមេរិកទាក់ទងនឹងបរិយាកាសអំណោយផល (ធាតុចេញទី I); ២០១,១ លានដុល្លារអាមេរិកសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជាមូលដ្ឋាន ដោយមិនរួមបញ្ចូលទាំងក្នុងស្ថាប័ន (ធាតុចេញទី II); ៧៦,០ លានដុល្លារអាមេរិកសម្រាប់អនាម័យជាមូលដ្ឋាន ដោយមិនរួមបញ្ចូលទាំងក្នុងស្ថាប័ន (ធាតុចេញទី III); និង ០,៤ លានដុល្លារអាមេរិកសម្រាប់ការផ្លាស់ប្តូរឥរិយាបថ (ធាតុចេញទី IV)។ ការប៉ាន់ស្មាននេះ មិនទាន់បូកបញ្ចូលតម្រូវការចំណាយលើបុគ្គលិកនិងចំណាយប្រតិបត្តិការផ្សេងទៀតដែលពាក់ព័ន្ធនៅឡើយទេ[៣៤] ។ បន្ថែមលើតម្រូវការថវិកាសាធារណៈសរុបនេះ គេរំពឹងថាការរួមចំណែកពីគ្រួសារ នឹងមានចំនួនប្រមាណ ២៦៦,៨ លានដុល្លារអាមេរិក (១០៦,៣ លានដុល្លារអាមេរិក សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនៅជនបទនិង ១៦០,៤ លានដុល្លារសម្រាប់អនាម័យនៅជនបទ) ដែលរួមចំណែកដល់ការចំណាយលើការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ ឧទាហរណ៍ ដូចជាការទិញបង្គន់ ឬក៏ទិញសម្ភារបង្គន់អនាម័យ។ តារាងទី ៧ សង្ខេបពីតម្រូវការធនធានហិរញ្ញវត្ថុសាធារណៈប៉ាន់ស្មាន ផ្អែកតាមធាតុចេញរបស់ NAP II (២០១៩-២០២៣។ ការប៉ាន់ប្រមាណតម្រូវការចំណាយប្រចាំឆ្នាំ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី II ។

**តារាងទី ៧: តម្រូវការចំណាយប៉ាន់ស្មាន ផ្អែកតាមធាតុចេញ**

| កូដសម្គាល់ | បរិយាយ | តម្រូវការចំណាយសរុប (ដុល្លារ USD) |
|---|---|---|
| ធាតុចេញទី I | MRD, PDRDs, PWGs និងអាជ្ញាធរមូលដ្ឋាន បានពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការនិងសម្របសម្រួល ដើម្បីស្នើសុំការវិភាជថវិកាបន្ថែមទៀត និងត្រួតពិនិត្យ តាមដានកម្មវិធី RWSSH រួមទាំងក្នុងស្ថាប័ន (សាលារៀននិងមណ្ឌលសុខភាព) និងក្នុងពេលមានគ្រោះអាសន្ន។ | ៣.០២៥.២៨៥ |
| ធាតុចេញទី II | ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម និងតំបន់ដែលប៉ះពាល់ដោយសារធាតុអាសេនិក ទទួលបានកាន់តែច្រើនប្រកបដោយសមធម៌ និងនិរន្តរភាពនូវសេវាទឹកសម្រាប់ផឹកដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | ២០១.១៦៦.១១៩ |

[៣៣] ថវិកាសាធារណៈរួមបញ្ចូលថវិកាមានប្រភពក្នុងស្រុក (រាជរដ្ឋាភិបាល) និងក្រៅស្រុក (ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល) ។
[៣៤] ត្រូវបានប៉ាន់ស្មានថាមានប្រមាណ ២១ %នៃតម្រូវការចំណាយរបស់កម្មវិធីសរុប ផ្អែកលើ NAPI ២០១៤-២០១៨ ។

| | | |
|---|---|---|
| ធាតុចេញទី III | ប្រជាពលរដ្ឋនៅជនបទ រួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈម ទទួលបានកាន់តែច្រើនប្រកបដោយសមធម៌និងនិរន្តរភាពនូវសេវាអនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព | ៧៦.០៣៨.០៩១ |
| ធាតុចេញទី IV | ប្រជាពលរដ្ឋនៅជនបទ កែលម្អឥរិយាបថអនាម័យ | ៩៣៥.៩៨១ |
| សរុប | តម្រូវការចំណាយសម្រាប់កម្មវិធី | ២៩០.៦៦៩.៩៣៥ |

វិធីសាស្ត្រដែលបានប្រើសម្រាប់ការប៉ាន់ប្រមាណតម្រូវការថវិកា NAP II គឺ:

- ធ្វើការកំណត់អន្តរាគមន៍ដែលពាក់ព័ន្ធក្នុង NAP II ដែលបានប៉ាន់ប្រមាណចំណាយក្នុង NAP I ជាមួយនឹងចំណាយក្នុងមួយឯកតានិងកែតម្រូវបន្ថែមអត្រាអតិផរណា[៣៥] ហើយប្រើប្រាស់វាជាមូលដ្ឋានសម្រាប់ការប៉ាន់ស្មាន ជាពិសេសសកម្មភាពដែលទាក់ទងនឹងបរិយាកាសអំណោយផល (ធាតុចេញទី I) សកម្មភាពជំរុញផ្សព្វផ្សាយសម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ (ធាតុចេញទី II និងធាតុចេញទី III) និងការផ្លាស់ប្ដូរឥរិយាបថ (ធាតុចេញទី IV)។ សម្រាប់សកម្មភាពដែលមិនបានប៉ាន់ប្រមាណនៅក្នុង NAP I ការប៉ាន់ប្រមាណត្រូវធ្វើឡើងដោយផ្អែកលើបទពិសោធន៍ការអនុវត្តកម្មវិធីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ យោងលើទិន្នន័យដែលផ្ដល់ឱ្យដោយភាគីពាក់ព័ន្ធនៅក្នុងវិស័យ។
- ធ្វើបច្ចុប្បន្នភាពប៉ាន់ប្រមាណចំណាយក្នុងមនុស្សម្នាក់ ក្នុងរបាយការណ៍វាយតម្លៃការផ្ដល់សេវារបស់ធនាគារពិភពលោក (២០១៥) សម្រាប់ជម្រើសបច្ចេកវិទ្យាដែលបានកំណត់សម្រាប់ការវិនិយោគមូលធនការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ[៣៦] និងការប្រតិបត្តិ ការថែទាំ ដោយបានរួមបញ្ចូលអត្រាអតិផរណាកម្រិត៣,២៩% ហើយអនុវត្តន៍ការប៉ាន់ស្មានចំណាយគ្រួសារនិងចំណាយសាធារណ:។
- បូកថែមតម្រូវការចំណាយបន្ថែម សម្រាប់ការវិនិយោគមូលធនលើតំបន់បរិស្ថានប្រឈមសម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ ដោយយោងទៅលើចំនួនប្រជាពលរដ្ឋរស់នៅតំបន់បរិស្ថានប្រឈមទាំងនោះដែលរងផលប៉ះពាល់មធ្យមនិងប៉ះពាល់ធ្ងន់ធ្ងរ[៣៧] ដោយប្រើប្រាស់បដិភាគចំណាយប៉ាន់ស្មានសម្រាប់ការវិភាគសេណារីយ៉ូឧបត្ថម្ភធនលើអនាម័យ (សេណារីយ៉ូទី១)[៣៨] ។ ការផ្គត់ផ្គង់ទឹក តម្រូវការចំណាយបន្ថែមសម្រាប់តំបន់បរិស្ថានប្រឈម[៣៩] ត្រូវបានប៉ាន់ប្រមាណដោយប្រើប្រាស់សមាមាត្រដូចគ្នា នឹងអនាម័យដែរ។

[៣៥] ប្រើប្រាស់អត្រាអតិផរណា ៣,២៩% មធ្យមភាគអត្រាអតិផរណាក្នុងរវាងឆ្នាំ ២០១០ និងឆ្នាំ ២០១៩

[៣៦] តម្រូវការវិនិយោគមូលធនរួមបញ្ចូលតម្រូវការវិនិយោគសាធារណ: ក្នុងស្រុក (រាជរដ្ឋាភិបាល) និងក្រៅស្រុក (ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល) ព្រមទាំងការវិនិយោគមូលធនរបស់ក្រុមគ្រួសារ

[៣៧] របាយការណ៍វាយតម្លៃប្រទេសកម្ពុជា ស្ដីពីអនាម័យដែលមានតម្លៃសមស្របនៅក្នុងតំបន់លំបាកនៅក្នុងប្រទេសកម្ពុជា និងឡាវ ជំហានទី១៖ ការកំណត់តំបន់លំបាក ប្រជាជនដែលរងផលប៉ះពាល់ និងជម្រើសអនាម័យក្នុងតំបន់ (កម្មវិធីទឹក និងអនាម័យរបស់ធនាគារពិភពលោក ឆ្នាំ ២០១១)

[៣៨] របាយការណ៍វិភាគសេណារីយ៉ូការឧបត្ថម្ភធន ស្ដីពីអនាម័យ

[៣៩] ការពិគ្រោះយោបល់ជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងជាមួយក្រុមការងារគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលផ្ដល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី ថវិកាបន្ថែមសម្រាប់ការផ្គត់ផ្គង់ទឹកដែលពិចារណាពីលក្ខខណ្ឌប្រែប្រួលអាកាសធាតុគឺមានភាពខុសគ្នារវាងបច្ចេកវិទ្យាមួយទៅបច្ចេកវិទ្យាមួយទៀត ឧទាហរណ៍ សម្រាប់ស្រះសហគមន៍ថវិកាត្រូវការបន្ថែមនឹងអាច ៥០% ខណ:ដែលអណ្ដូងខួងដែលមានភាពធន់ទៅនឹងអាកាសធាតុអាចនឹងច្រើនជាងពីរដង

តារាងខាងក្រោមបង្ហាញសមាសធាតុចំណាយដែលបានប្រើក្នុងការប៉ាន់ស្មានដោយប្រៀបធៀបជាមួយ NAP I និង SDA

**តារាងទី ៨: សមាសធាតុ វិធីសាស្ត្រប៉ាន់ស្មានចំណាយ NAP II ដោយប្រៀបធៀបជាមួយ NAP I និង SDA**

| Element | NAP II | NAP I | SDA |
|---|---|---|---|
| សន្មតទិន្នន័យដើមគ្រានិងចុងគ្រា | 2019 (CSES 2017) - 2023 | 2014 (CSES 2013) -2018 | 2015 (JMP 2012) - 2025 |
| ព្យាករណ៍កំណើនប្រជាពលរដ្ឋក្នុងអំឡុងពេលផែនការ | បានរួមបញ្ចូល | មិនដឹង | បានរួមបញ្ចូល |
| ចំណាយមូលធន (សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតការរស់នៅស្អាត និងអនាម័យថ្មី) | បានរួមបញ្ចូល | មិនបានរួមបញ្ចូល | បានរួមបញ្ចូល |
| អាយុកាល/រំលោះ/ចំណាយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ ផ្លាស់ប្តូរសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យដែលមានស្រាប់ | បានរួមបញ្ចូល | មិនបានរួមបញ្ចូល | បានរួមបញ្ចូល |
| ចំណាយប្រតិបត្តិនិងជួសជុល | បានរួមបញ្ចូល | មិនបានរួមបញ្ចូល | បានរួមបញ្ចូល |
| ចំណាយក្នុងមួយឯកតាត្រូវបានកែតម្រូវសម្រាប់អត្រាអតិផរណា | បានរួមបញ្ចូល | មិនបានរួមបញ្ចូល | មិនបានរួមបញ្ចូល |
| ទឹកពិសារដបបានបញ្ចូលនៅក្នុងផែនការចុងគ្រា | បានរួមបញ្ចូល | មិនបានរួមបញ្ចូល | មិនបានរួមបញ្ចូល |
| សកម្មភាពផ្សព្វផ្សាយការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យ | បានរួមបញ្ចូល | ប៉ាន់ស្មានថាបានរួមបញ្ចូល (សំណួរទាក់ទងការអនុវត្ត ឱ្យបានស្របគ្នាទាំងអស់) | មិនបានរួមបញ្ចូល (សន្មតបានបញ្ចូលជាផ្នែកនៃថវិកាចំណាយប្រតិបត្តិរបស់ MRD |
| កែតម្រូវចំណាយសម្រាប់ការបន្សាំនិងភាពធន់ នឹងអាកាសធាតុដែលបានកើនឡើងចំពោះតំបន់បរិស្ថានប្រឈម | បានរួមបញ្ចូល | មិនបានរួមបញ្ចូល | មិនបានរួមបញ្ចូល |
| ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យក្នុងស្ថាប័ន (សាលារៀន និងមូលដ្ឋានសុខាភិបាល) | មិនបានរួមបញ្ចូល | អនុវត្តឱ្យបានស្របគ្នាទាំងអស់ | មិនបានរួមបញ្ចូល |

៣៨ របាយការណ៍វិភាគសេណារីយ៉ូការឧបត្ថម្ភធន ស្តីពីអនាម័យ

៣៩ ការពិគ្រោះយោបល់ជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងជាមួយក្រុមការងារគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី ថវិកាបន្ថែមសម្រាប់ការផ្គត់ផ្គង់ទឹកដែលពិចារណាពីលក្ខខណ្ឌប្រែប្រួលអាកាសធាតុគឺមានភាពខុសគ្នារវាងបច្ចេកវិទ្យាមួយទៅបច្ចេកវិទ្យាមួយទៀត ឧទាហរណ៍ សម្រាប់ស្រះសហគមន៍ថវិកាត្រូវការបន្ថែមនឹងអាច ៥០% ខណៈដែលអណ្តូងខួងដែលមានភាពធន់ទៅនឹងអាកាសធាតុអាចនឹងច្រើនជាងពីរដង

ប្រភពថវិកាដើម្បីគាំទ្រការអនុវត្ត NAPII នឹងរួមបញ្ចូលថវិកាជាតិ (ត្រូវបានចាត់ថ្នាក់ជាថវិកាសាធារណៈក្នុងស្រុក) ថវិកាបានមកពីដៃគូអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិល (ត្រូវបានចាត់ថ្នាក់ជាថវិកាសាធារណៈក្រៅស្រុក) និងបដិភាគពីក្រុមគ្រួសារ។ តារាងទី៩ ខាងក្រោមបង្ហាញពីប្រភពថវិកាប្រចាំឆ្នាំ និងការវិភាគគម្លាតថវិកាដើម្បីសម្រេចគោលដៅគ្របដណ្តប់ដែលបានកំណត់នៅក្នុង NAP II ។ យោងទៅលើទិន្នន័យបច្ចុប្បន្ន ការវិនិយោគមូលធនសាធារណៈដែលបានប៉ាន់ប្រមាណ (ទាំងក្នុងស្រុក និងក្រៅស្រុក) គឺប្រមាណជា ២០,៨ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ (៣៧,១% នៃតម្រូវការថវិកាសាធារណៈ)។ នេះបន្សល់ឱ្យវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ នូវគម្លាតថវិកាប្រហែលជា ៣៥,៣ លានដុល្លារអាមេរិក (គ្របដណ្តប់ប្រហែលជា ៦២,៩% នៃតម្រូវការថវិកាសាធារណៈ)។ បន្ថែមលើនេះទៀតថវិកាបដិភាគប៉ាន់ស្មានរំពឹងថា នឹងបានពីក្រុមគ្រួសារសម្រាប់ការចំណាយមូលធន ការប្រតិបត្តិ និងថែទាំ ប្រមាណជា ៥៣,៨ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

**តារាងទី ៩: ចំណាយប៉ាន់ស្មានប្រភពថវិកាសាធារណៈប្រចាំឆ្នាំ និងគម្លាតថវិកា ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ**

| ចំណាយប៉ាន់ស្មានប្រភពថវិកាសាធារណៈប្រចាំឆ្នាំនិងគម្លាតថវិកា សម្រាប់ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ | លានដុល្លារ អាមេរិក/មួយឆ្នាំ | % នៃថវិកាប៉ាន់ស្មាន សរុប |
|---|---|---|
| I). ប្រភពថវិកា | | |
| សាធារណៈក្នុងស្រុក | | |
| MRD[៩០] | ៨,៨ | ៨,៦% |
| សាធារណៈក្រៅស្រុក | | |
| គម្រោងហិរញ្ញប្បទានក្រៅប្រទេសរបស់ MRD (មានហិរញ្ញប្បទាន)[៩១] | ៧,៣ | ១២,៩% |
| គម្រោងហិរញ្ញប្បទានក្រៅប្រទេសរបស់ MRD (មិនទាន់មានហិរញ្ញប្បទាន) | | |
| ជំនួយអភិវឌ្ឍន៍ផ្លូវការតាមរយៈ NGOs[៩២] | ៨,៧ | ១៥,៥% |
| ថវិកាសាធារណៈប្រចាំឆ្នាំប៉ាន់ស្មានសរុប | ២០,៨ | ៣៧,១% |
| II). ចំណាយ | | |
| ចំណាយ NAP II/មួយឆ្នាំ | ៥៦,១ | ១០០% |
| III). គម្លាតថវិកា | | |
| គម្លាតថវិកាប៉ាន់ស្មានសរុបប្រចាំឆ្នាំ | ៣៥,៣ | ៦២,៩% |
| IV). ចំណាយមូលធន ចំណាយប្រតិបត្តិ និងថែទាំប៉ាន់ស្មានពីក្រុមគ្រួសារ | | |
| បដិភាគរំពឹងបានពីក្រុមគ្រួសារ[៩៣] | ៥៣,៨ | |

[៩០] ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ ២០១៩-២០២១ សម្រាប់ទិន្នន័យឆ្នាំ ២០២០ និង ២០២១ និងថវិកាសង្ខេបឆ្នាំ ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងរបាយការណ៍វិភាគថវិកាកម្មវិធីឆ្នាំ ២០១៨ តាម ២៥ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី/ខេត្ត

[៩១] ច្បាប់ថវិកាឆ្នាំ ២០១៩

[៩២] RGC CDC Database

[៩៣] NAP II ការគណនាយោងលើវិធីសាស្ត្ររបស់របាយការណ៍ SDA

វិស័យនេះនឹងត្រូវខិតខំប្រឹងប្រែង ដើម្បីកែលម្អស្ថានភាពហិរញ្ញវត្ថុតាមរយៈ៖

1. ការពង្រឹងការស្វែងរកការគាំទ្រដើម្បីកំណត់និងកៀរគរធនធានពីគ្រប់ប្រភពទាំងអស់ រួមបញ្ចូលទាំងភាពជាដៃគូរវាងវិស័យឯកជននិងវិស័យសាធារណៈ។
2. កៀរគរធនធានថ្នាក់ក្រោមជាតិសម្រាប់ RWSSH
3. ការតាមដានការវិភាជថវិកា ការចំណាយលើសេវាការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទតាមរយៈ ថវិកាកម្មវិធី ដែលរួមបញ្ចូលទាំងការតាមដានកាន់តែប្រសើរនៅថ្នាក់ក្រោមជាតិជាបន្តបន្ទាប់
4. ការពង្រឹង ការតាមដានហិរញ្ញវត្ថុក្នុងការរៀបចំសម្របសម្រួលវិស័យ
5. ធ្វើការចងក្រងតម្លៃនៃថវិកាសម្រាប់ការវិនិយោគក្នុងវិស័យទឹកស្អាត និងអនាម័យ

# ៦. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

តារាងម៉ាទ្រីសត្រួតពិនិត្យ តាមដានការអនុវត្តដែលដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធទី I បង្ហាញពីចំណុចដៅប្រចាំឆ្នាំដែលបានកំណត់សម្រាប់សូចនាករនីមួយៗនៃ RWSSH NAP II ។ មានសូចនាករលទ្ធផលរំពឹងទុកចំនួន៥ និងសូចនាករធាតុចេញចំនួន៨៧ រួមទាំង សូចនាករចំនួន៣៥ ដែលត្រូវបានកំណត់ដោយ PAPs II។ តារាងបន្ថែមមួយ ជាមួយ នឹងនិយមន័យនៃសូចនាករនីមួយៗ វិធីសាស្ត្រ និងភាពញឹកញាប់នៃការប្រមូលទិន្នន័យ និងស្ថាប័នទទួលខុសត្រូវ ត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ IA។ សូចនាករទាំងនេះ នឹងបង្កើតជាមូលដ្ឋានសម្រាប់ត្រួតពិនិត្យ តាមដានវឌ្ឍនភាពឆ្ពោះទៅរកចំណុចដៅរបស់ NAP II។

ដំណាក់កាលទី១នៃ RWSSH MIS ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៧/២០១៨ ហើយបានចាប់ផ្តើមបង្កើតទិន្នន័យនិងព័ត៌មានអំពីសូចនាករសំខាន់ៗចំនួន៦ នៅក្រោមកម្មវិធី NAP I ដែល នឹងស្ថិតនៅក្រោម NAP II ផងដែរ។ MIS ថ្មីនេះត្រូវបានពង្រឹងនិងពង្រីកដើម្បីគ្របដណ្តប់លើសូចនាករសំខាន់ៗបន្ថែមទៀតក្នុងអំឡុងពេល NAP II ។

ស្ថានភាពនៃសូចនាករ នឹងត្រូវបានរាយការណ៍ជាទៀងទាត់។ ការរាយការណ៍ផ្អែកលើលទ្ធផល ជាមួយព័ត៌មានបែបគុណភាពនិងបរិមាណ ស្តីពីវឌ្ឍនភាពឆ្ពោះទៅរកធាតុចេញនិងលទ្ធផលរំពឹងទុក រួមទាំងព័ត៌មានអំពីភាពជោគជ័យនិងបញ្ហាប្រឈម នឹងត្រូវបានជំរុញជាផ្នែកមួយនៃការពិនិត្យឡើងវិញនៃលទ្ធផលការអនុវត្តប្រចាំឆ្នាំ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនិងការពិនិត្យឡើងវិញចុងក្រោយនៃ NAP II និង PAPs II។ ការត្រួតពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ធានាតម្លាភាពនិងគណនេយ្យភាព។ កាលវិភាគសម្រាប់ការពិនិត្យឡើងវិញលើលទ្ធផលនៃការអនុវត្ត ត្រូវបានបង្ហាញនៅក្នុងតារាងទី ៨ ។

**តារាងទី ១០: កាលវិភាគសម្រាប់ការពិនិត្យឡើងវិញលើលទ្ធផលនៃការអនុវត្ត**

| | ការពិនិត្យឡើងវិញប្រចាំត្រីមាស | ការពិនិត្យឡើងវិញប្រចាំឆ្នាំ | ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ | ការពិនិត្យឡើងវិញចុងក្រោយ |
|---|---|---|---|---|
| កាលវិភាគ | ចុងបញ្ចប់នៃត្រីមាសនីមួយៗ | វិច្ឆិកា/ធ្នូសម្រាប់រាយការណ៍ជូនសន្និបាតក្រសួងអភិវឌ្ឍន៍ជនបទ | ២០២១ | ត្រីមាសទី២នៃឆ្នាំ២០២៣ |

| | ការពិនិត្យឡើងវិញប្រចាំត្រីមាស | ការពិនិត្យឡើងវិញប្រចាំឆ្នាំ | ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ | ការពិនិត្យឡើងវិញចុងក្រោយ |
|---|---|---|---|---|
| វិធីសាស្ត្រ | • PAPs II: តាមរយៈកិច្ចប្រជុំ PWGs ពិនិត្យឡើងវិញលើសូចនាករសំខាន់ៗ<br>• NAP: តាមរយៈកិច្ចប្រជុំ TWG, ពិនិត្យឡើងវិញលើសូចនាករសំខាន់ៗ | • PAPs II: កិច្ចប្រជុំ PWG ជាមួយតំណាងថ្នាក់ជាតិ ដើម្បីពិនិត្យឡើងវិញលើចំណុចដៅនៃលទ្ធផលដែលសម្រេចបានប្រចាំឆ្នាំ<br>• NAP II: លេខាធិការដ្ឋាន TWG (TWG-S) នឹងដឹកនាំការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើម៉ាទ្រីសត្រួតពិនិត្យតាមដានលទ្ធផលប្រចាំឆ្នាំនៅក្នុងអំឡុងពេល វិបស្សនារបស់វិស័យ<br>• លទ្ធផលនៃការពិនិត្យឡើងវិញប្រចាំឆ្នាំនឹងត្រូវបង្ហាញដល់ TWG និងសន្និបាតរបស់ក្រសួងអភិវឌ្ឍន៍ជនបទ | • ការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើ PAPs និង NAP<br>• កិច្ចប្រជុំ PWGs និង TWG-S/សិក្ខាសាលា | • ការវាយតម្លៃគ្រប់ជ្រុងជ្រោយដោយឯករាជ្យ |

# ៧.សន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្ត RWSSH NAP និង PAPs ឆ្នាំ២០១៩-២០២៣ ជាការបន្តពី NAP និង PAPs ឆ្នាំ២០១៤-២០១៨ ដើម្បីផ្តល់ក្របខណ្ឌមួយក្នុងការសម្រេចបានលទ្ធផលរំពឹងទុកៈ “ប្រជាពលរដ្ឋនៅជនបទទទួលបានកាន់តែច្រើនថែមទៀត និងប្រើប្រាស់សេវាទឹកសម្រាប់ផឹក ការរស់នៅស្អាត និងអនាម័យប្រកបដោយសមធម៌ និរន្តរភាពនិងសុវត្ថិភាព”។ លទ្ធផលរំពឹងទុកនេះគឺស្របគ្នាជាមួយចក្ខុវិស័យនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦របស់កម្ពុជា។

ផែនការនេះគ្របដណ្តប់លើធាតុចេញចំនួន៤ ដែលត្រូវសម្រេចឱ្យបានតាមរយៈចង្កោមសកម្មភាពជាក់លាក់ឆ្ពោះទៅរកការសម្រេចបានលទ្ធផលរំពឹងទុកខាងលើ។

- ធាតុចេញទី I: MRD, PDRDs, PWGs និងអាជ្ញាធរមូលដ្ឋាន បានពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងសម្របសម្រួល ដើម្បីស្នើសុំការវិភាជថវិកាបន្ថែមទៀតនិងត្រួតពិនិត្យ តាមដានកម្មវិធី RWSSH រួមទាំងក្នុងស្ថាប័ន និងក្នុងពេលមានគ្រោះអាសន្ន។
- ធាតុចេញទីII:ប្រជាជននៅជនបទរួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈមនិងតំបន់ដែលប៉ះពាល់ដោយសារធាតុអាសេនិកទទួលបានកាន់តែច្រើន ប្រកបដោយសមធម៌និងនិរន្តរភាពនូវសេវាទឹកសម្រាប់ផឹកដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព។
- ធាតុចេញទីIII: ប្រជាពលរដ្ឋនៅជនបទរួមទាំងអ្នកដែលរស់នៅក្នុងបរិស្ថានប្រឈមទទួលបានកាន់តែច្រើនប្រកបដោយសមធម៌និងនិរន្តរភាពនូវសេវាអនាម័យដែលបានត្រូវគ្រប់គ្រងប្រកបដោយសុវត្ថិភាព
- ធាតុចេញទី IV: ប្រជាជននៅជនបទផ្លាស់ប្តូរឥរិយាបថអនាម័យទាក់ទង នឹងទឹកសម្រាប់ផឹកដែលមានសុវត្ថិភាព ប្រើប្រាស់បង្គន់អនាម័យនិងការលាងសម្អាតដៃនឹងសាប៊ូ។

NAP និងPAPs II នឹងត្រូវបានអនុវត្តតាមរយៈស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នក្រោមឱវាទដែលមានអាណត្តិក្នុងការសម្របសម្រួល ជួយសម្រួលអនុវត្ត ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃការអភិវឌ្ឍ RWSSH។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយ នឹងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ ទាំងក្នុងនិងក្រៅប្រទេស ដើម្បីអនុវត្តផែនការទាំងនេះ។ ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលស្គាល់តួនាទីដ៏សំខាន់ដែលវិស័យឯកជនមាន នៅក្នុងការអភិវឌ្ឍវិស័យនេះ ហើយនឹងពង្រឹងការចូលរួមរបស់វិស័យឯកជននៅក្នុងការអនុវត្តផែនការទាំងនេះ។

ដើម្បីធានាភាពច្បាស់លាស់នៃដំណើរការអនុវត្តឆ្នាំទី១ នឹងផ្តោតការយកចិត្តទុកដាក់លើការរៀបចំ និងការផ្សព្វផ្សាយអំពីការអនុវត្ត និងគោលការណ៍ណែនាំបច្ចេកទេស ការបំភ្លឺអំពីតួនាទី និងការទទួលខុសត្រូវចំពោះ NAP និង PAPs ក្នុងចំណោមបុគ្គលិកសំខាន់ៗរបស់ DRHC និង DRWS និងការចាប់ផ្តើមសកម្មភាពអភិវឌ្ឍន៍សមត្ថភាព។ គោលការណ៍ណែនាំនឹងត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលការណ៍ណែនាំស្រដៀងគ្នាដែលមានស្រាប់នៅក្នុងវិស័យ RWSSH ក៏ដូចជាគំនិតផ្តួចផ្តើមនានាពីវិស័យដែលពាក់ព័ន្ធដូចជាៈ

ការពង្រឹង MIS មានសារសំខាន់សម្រាប់ការត្រួតពិនិត្យ តាមដាននិងការអនុវត្តប្រកបដោយប្រសិទ្ធភាព ក៏ដូចជា រួមចំណែកដល់អភិបាលកិច្ចល្អនៅក្នុងវិស័យនេះ ជាពិសេស ការលើកកម្ពស់គណនេយ្យភាព។ ការពិនិត្យឡើងវិញជាទៀងទាត់លើវឌ្ឍនភាពឆ្ពោះទៅរកចំណុចដៅ ការសន្មតដែលបានរៀបរាប់ខាងលើ និងព្រឹត្តិការណ៍សិក្សារៀនសូត្រនានា ត្រូវបានគេរំពឹងថា នឹងធ្វើឱ្យមានភាពប្រសើរឡើងជាបន្តបន្ទាប់នៅក្នុងការអនុវត្តផែនការនេះ។ ថវិកាកម្មវិធី ត្រូវបានរំពឹងនឹងធានាថាធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ផ្ដោតទាំងស្រុងលើលទ្ធផល ហើយថា ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផល ត្រូវបានប្រើប្រាស់ដើម្បីកែសម្រួលផែនការនិងការអនុវត្តកម្មវិធី។

បន្ថែមពីលើចំណុចដៅសម្រាប់សេវាជាមូលដ្ឋាន NAP និង PAPs ឆ្នាំ ២០១៩-២០២៣ មានបំណងសម្រេចឱ្យបានចំណុចដៅខ្ពស់នៃសេវាផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទដែលមានការគ្រប់គ្រងដោយសុវត្ថិភាព។ កិច្ចការនេះត្រូវការជំនាញថ្មីសម្រាប់ធ្វើការតាក់តែង រៀបចំផែនការនិងការត្រួតពិនិត្យ តាមដាន។

ជារួម ជោគជ័យនៃការអនុវត្ត NAP និង PAPs ឆ្នាំ ២០១៩-២០២៣ តម្រូវឱ្យមានការកែលម្អសមត្ថភាព ភាពមានវិជ្ជាជីវៈខ្ពស់ជាងមុន ការសម្របសម្រួលខ្លាំងជាងមុន នវានុវត្តន៍និងការប្ដេជ្ញាចិត្តក្នុងការដោះស្រាយវិសមភាព ព្រមទាំងកែលម្អអភិបាលកិច្ចរបស់វិស័យនេះ។

# ឧបសម្ព័ន្ធទី I: ម៉ាទ្រីសត្រួតពិនិត្យ តាមដានលទ្ធផលនៃការអនុវត្ត

កំណត់សម្គាល់៖ សូចនាករជាអក្សរពណ៌ខៀវ មានន័យថា ជាបញ្ហាអន្តរវិស័យ។

| ចង្កោម សកម្មភាព | សូចនាករ | លេខកូដ សូចនាករ នៅក្នុងPAP | អង្គភាព | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ទិន្នន័យ គោលឆ្នាំ ២០១៨ (ប្រភពទិន្នន័យ) | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ធាតុចេញទី I: ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ក្រុមការងារបច្ចេកទេសរាជធានី ខេត្ត (MRD, PDRDs, PWGs) និងអាជ្ញាធរមូលដ្ឋាន បានពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងសម្របសម្រួល ដើម្បីស្នើសុំការវិភាជថវិកាបន្ថែមទៀត និងត្រួតពិនិត្យតាមដានកម្មវិធីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ(RWSSH)រួមទាំងក្នុងស្ថាប័ន (សាលារៀន និងគ្រឹះស្ថានថែទាំសុខភាព) និងក្នុងពេលមានគ្រោះអាសន្ន។ | | | | | | | | | | |
| I. ក កែលម្អដំណើរការនៃរចនាសម្ព័ន្ធសម្របសម្រួល RWSSH នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជាពិសេសទៅលើទំនាក់ទំនងអន្តរវិស័យ | 1.1 ចំនួន PWGs ដែលរៀបចំកិច្ចប្រជុំយ៉ាងតិចបីដង រួមទាំងកិច្ចប្រជុំប្រចាំឆ្នាំដើម្បីត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃPAP II; កិច្ចប្រជុំយ៉ាងតិចមួយដងដាក់បញ្ចូលរបៀបវារៈអំពី RWSSH និងអាហារូបត្ថម្ភ | 1.1 | ខេត្ត | 25 | 25 | 25 | 25 | 25 | 0 (ការពិនិត្យឡើងវិញលើ PAP I) | PWGs |
| | 1.2 ចំនួនកិច្ចប្រជុំសម្របសម្រួលអន្តរវិស័យ (TWG, RWSSH ក្នុងសាលារៀន RWSSH ក្នុងគ្រឹះស្ថានថែទាំសុខភាព RWSSH និងអាហារូបត្ថម្ភ) | N/A | កិច្ចប្រជុំ | យ៉ាងតិច ៣ x ក្នុងមួយរចនាសម្ព័ន្ធ | យ៉ាងតិច ៣ x ក្នុងមួយរចនាសម្ព័ន្ធ | យ៉ាងតិច ៣ x ក្នុងមួយរចនាសម្ព័ន្ធ | យ៉ាងតិច ៣ x ក្នុងមួយរចនាសម្ព័ន្ធ | យ៉ាងតិច ៣ x ក្នុងមួយរចនាសម្ព័ន្ធ | TWG មានកិច្ចប្រជុំប្រចាំត្រីមាស, ក្រុមផ្សេងទៀត (others) ជួបប្រជុំមិនទៀងទាត់ | TWG និង TWG-S |
| | 1.3 ចំនួនកិច្ចប្រជុំសម្របសម្រួលថ្នាក់វិស័យ/ព្រឹត្តិការណ៍សិក្សារៀនសូត្រ (TWG-S/ SWGs - RuSH, RWS, អនាម័យនៅក្នុងបរិស្ថានប្រឈម, WATSAN។ល។) | N/A | កិច្ចប្រជុំ / ព្រឹត្តិការណ៍ | យ៉ាងតិច ៣ ដង | យ៉ាងតិច ៣ ដង | យ៉ាងតិច ៣ ដង | យ៉ាងតិច ៣ ដង | យ៉ាងតិច ៣ ដង | TWG-S ជួបប្រជុំប្រចាំត្រីមាស; RuSH និង WATSAN: ប្រចាំខែ; ការផ្គត់ផ្គង់ទឹកស្អាតនៅជនបទអនាម័យក្នុងតំបន់ដែលលំបាក: មិនទៀងទាត់ | TWG-SSWGs នៃ RuSH, ផ្គត់ផ្គង់ទឹកស្អាតជនបទនៅក្នុងតំបន់ដែលលំបាក និង WATSAN |

| ចង្កោម សកម្មភាព | សូចនាករ | លេខកូដ សូចនាករ នៅក្នុងPAP | អង្គភាព | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ទិន្នន័យ គោលឆ្នាំ ២០១៨ (ប្រភពទិន្នន័យ) | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| I. ខ អភិវឌ្ឍន៍ សមត្ថភាពអំពី RWSSH ផ្អែកលើ CDP [៩៩] | 1.4 ចំនួន PWGs បញ្ចប់ការបណ្តុះបណ្តាល ឬការសិក្សាផ្អែកលើ CDP ដែលមានការចូលរួមពីស្ត្រីយ៉ាងតិច ៣០% | N/A | PWG | ១២ | ២៥ | ២៥ | បានបញ្ចប់ | បានបញ្ចប់ | N/A | PWGs |
| | 1.5 ចំនួនរដ្ឋបាលស្រុកដែលមានមន្ត្រីទទួលខុសត្រូវលើ RWSSH បានបញ្ចប់វគ្គបណ្តុះបណ្តាល ផ្អែកលើ CDP ដែលមានការចូលរួមពីស្ត្រីយ៉ាងតិច៣០% | ១,២ | ស្រុក | ៩០ | ១០០ | ១៦៥ | បានបញ្ចប់ | បានបញ្ចប់ | N/A | PWGs |
| | 1.6 ចំនួនបុគ្គលិក PDRDs ទទួលខុសត្រូវលើ RWSSH បានបញ្ចប់វគ្គបណ្តុះបណ្តាលផ្អែកលើ CDP ដែលមានការចូលរួមពីស្ត្រីយ៉ាងតិច ៣០% | N/A | នាក់ | ២៥ | ៧៥ | បានបញ្ចប់ | បានបញ្ចប់ | បានបញ្ចប់ | N/A | PWGs |
